# ទំនាយ

## ពាក្យលំនាំ

ក្រោយព្រះយេស៊ូសោយទិវង្គត ចំនួនគ្រីស្តបរិស័ទបានកើនកាន់តែច្រើនឡើងៗ ហើយខ្ចាត់ខ្ចាយពាសពេញ ក្នុងមជ្ឈិមបូព៌ាទាំងមូល ព្រមទាំងនៅក្រុងរ៉ូមជារាជធានីរបស់ចក្រភពរ៉ូម៉ាំងដែរ។ ដោយគ្រីស្តបរិស័ទមិនព្រមគោរពតាមសាសនាពួកគេ ជាពិសេសមិនគោរពព្រះចៅអធិរាជរ៉ូម៉ាំងជាព្រះរបស់ខ្លួន អាជ្ញាធររ៉ូម៉ាំង និងអ្នកស្រុកនាំគ្នាស្អប់គ្រីស្តបរិស័ទកាន់តែខ្លាំងឡើងៗ។

ហេតុនេះហើយបានជាអាជ្ញាធររ៉ូម៉ាំងធ្វើបាបគ្រីស្តបរិស័ទយ៉ាងខ្លាំង រហូតដល់ទៅប្រហារជីវិតពួកគេមួយចំនួនធំទៀតផង។ នៅគ.ស.៦៤ព្រះចៅអធិរាជណេរ៉ុងបានចាប់គ្រីស្តបរិស័ទខ្លះជ្រលក់ក្នុងជ័រដុតដូចចន្លុះ ទ្រង់ឲ្យគេចាប់គ្រីស្តបរិស័ទខ្លះទៀតឲ្យសត្វសាហាវស៊ីទាំងរស់ ក្នុងកីឡាដ្ឋាន ឲ្យគេចាប់គ្រីស្តទូតសិលាយកទៅឆ្កាង និង យកគ្រីស្តទូតប៉ូលទៅកាត់ក។ល។ និង។ល។

គ្រីស្តបរិស័ទជាច្រើនអស់សង្ឃឹម ស្ទើរតែបាត់ជំនឿ។ ឃើញដូច្នេះ លោកយ៉ូហានក៏តែងកណ្ឌគម្ពីរវិវរណៈនេះដើម្បីលើកទឹកចិត្តពួកគេ។ លោកចង់ដាស់តឿនគ្រីស្តបរិស័ទកុំឲ្យខ្លាចអ្វីឡើយ! ព្រឹត្តិការណ៍ដ៏សែនវេទនាដែលកើតឡើងបង្ហាញ អំពីអំណាចរបស់មារដែលកំពុងច្បាំងប្រឆាំងនឹងព្រះជាម្ចាស់ ក៏ប៉ុន្តែព្រះគ្រីស្តមានជ័យជំនះហើយ! រីឯមារសាតាំង និងបរិវាររបស់វាមុខជាត្រូវបរាជ័យពុំខាន។ គ្រីស្តបរិស័ទដែលគេបានប្រហារជីវិតយ៉ាងសែនវេទនា នឹងសោយរាជ្យជាមួយព្រះអង្គ។ ព្រឹត្តិការណ៍ទាំងអស់ដែលកើតឡើង បង្ហាញពីគម្រោងការដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់ដែលចង់សង្គ្រោះមនុស្សលោក។

លោកយ៉ូហានពន្យល់សេចក្តីទាំងនេះ ដោយប្រើនិមិត្តរូបជាច្រើន តាមរបៀបជនជាតិអ៊ីស្រាអែល ជាពិសេសតាមរបៀបព្យាការីអេសេគីអែល និងដានីអែល។ ហេតុនេះហើយបានជាគម្ពីរវិវរណៈពិបាកយល់។

អត្ថន័យសំខាន់ៗមានដូចតទៅ គឺប្រជាជនរបស់ព្រះជាម្ចាស់តែងមានទុក្ខលំបាកតាំងពីដើមរៀងមក ដោយត្រូវគេធ្វើបាប តែព្រះយេស៊ូគ្រីស្តមានជ័យជំនះហើយ ហើយព្រះជាម្ចាស់នឹងប្រមូលគ្រីស្តបរិស័ទ ឲ្យមានអំណរសប្បាយរួមជាមួយព្រះអង្គអស់កល្បជានិច្ច។

រីឯនិមិត្តរូបសំខាន់ៗមានអត្ថន័យដូចតទៅ៖

**ពណ៌ស៖** ជាពណ៌របស់ព្រះជាម្ចាស់។ អស់អ្នកមានសម្លៀកបំពាក់សនៅស្ថានបរមសុខមានន័យថា គេបានចូលរួមជាមួយព្រះជាម្ចាស់ហើយ។

**មកុដ៖** ជានិមិត្តរូបនៃជោគជ័យ និង សិរីរុងរឿងរបស់គ្រីស្តបរិស័ទ។

**លេខ៣កន្លះ៖** គឺមិនគ្រប់លក្ខណៈមានន័យថា«ទុក្ខលំបាក» ឬ«ការបៀតបៀន»។ ជារយៈពេលមួយ ដែលស្តេចអង់ត្យូគូសអេពីផានបានធ្វើទុក្ខបៀតបៀនជនជាតិអ៊ីស្រាអែល(ដានីអែល៩.២)។

**លេខ៤៖** ជាលេខនៃពិភពលោកដែលមានបួនទិស។

**លេខ៧៖** ជាលេខគ្រប់លក្ខណៈឬពេញលក្ខណៈ ជាលេខតំណាងព្រះជាម្ចាស់។

**លេខ១២៖** និមិត្តរូបរបស់ជនជាតិអ៊ីស្រាអែលដែលមានកុលសម្ព័ន្ធ១២។

**លេខ១.០០០៖** មានន័យថា ច្រើនឥតគណនា។

**លេខ១៤៤.០០០៖** ជាលេខកុលសម្ព័ន្ធអ៊ីស្រាអែលទាំង១២ គុណនឹង១២ គុណនឹង១.០០០គឺមានន័យថា ច្រើនឥតគណនាពុំអាចរាប់បានឡើយ គឺជាចំនួនប្រជាជនថ្មីទាំងមូលរបស់ព្រះជាម្ចាស់។

**កូនចៀម៖** គឺព្រះយេស៊ូដែលត្រូវជនជាតិអ៊ីស្រាអែលធ្វើគុត ដូចគេធ្លាប់សម្លាប់កូនចៀមធ្វើយញ្ញបូជា ក្នុងឱកាសបុណ្យចម្លង។

**ស្ត្រី៖** ជានិមិត្តរូបនៃប្រជាជនរបស់ព្រះជាម្ចាស់ គឺព្រះសហគមន៍ជាមហេសីរបស់ព្រះគ្រីស្ត។

**នាគឬពស់:** ជានិមិត្តរូបរបស់មារសាតាំង។

**សត្វតិរច្ឆានដែលឡើងពីសមុទ្រ៖** ជានិមិត្តរូបរដ្ឋអំណាចរ៉ូម៉ាំង និង ជានិមិត្តរូបនៃរដ្ឋអំណាចទាំងឡាយ។

**សត្វតិរច្ឆានដែលផុសពីដី៖** ជានិមិត្តរូបស្តេចត្រាញ់ដែលបម្រើរដ្ឋអំណាចរ៉ូម៉ាំង និងមនោគមវិជ្ជាផ្សេងៗ។

**ក្រុងបាប៊ីឡូន៖** ជានិមិត្តរូបនៃក្រុងរ៉ូម។

## គម្រោងគម្ពីរវិវរណៈ

•សេចក្តីផ្តើម ១.១-៨
•និមិត្តហេតុអស្ចារ្យអំពីសំបុត្រផ្ញើទៅក្រុមគ្រីស្តបរិស័ទទាំងប្រាំពីរ ១.៩-៣.២២
•និមិត្តហេតុអស្ចារ្យ ត្រាំងដែលមានត្រាប្រាំពីរ ៤.១-៨.១
•និមិត្តហេតុអស្ចារ្យ ត្រែទាំងប្រាំពីរ ៨.២-១១.១៩
•និមិត្តហេតុអស្ចារ្យ សត្វនាគ និង សត្វតិរច្ឆានទាំងពីរ ១២.១-១៣.១៨

•និមិត្តហេតុអស្ចារ្យផ្សេងៗទៀត ១៤.១-១៥.៨
•និមិត្តហេតុអស្ចារ្យ អំពីពែងនៃព្រះពិរោធប្រាំពីរ ១៦.១-២១
•ការរំលាយក្រុងបាប៊ីឡូន បរាជ័យរបស់សត្វតិរច្ឆាន ព្រមទាំងព្យាការីក្លែងក្លាយ និងមារសាតាំង ១៧.១-២០.១០
•ការវិនិច្ឆ័យទោសនៅគ្រាចុងក្រោយ ២០.១១-១៥
•ផ្ទៃមេឃថ្មីផែនដីថ្មី និងក្រុងយេរូសាឡឹមថ្មី ២១.១-២២.៥
•អវសានកថា ២២.៦-២១

# ១ ហេតុការណ៍ដែលព្រះយេស៊ូគ្រីស្ត សម្តែងឲ្យលោកយ៉ូហានឃើញ

## សេចក្ដីផ្ដើម

១នេះជាហេតុការណ៍ ដែលព្រះយេស៊ូគ្រីស្ត
១បានសម្ដែងឲ្យឃើញ គឺព្រះជាម្ចាស់ប្រទាន
ឲ្យព្រះអង្គបង្ហាញព្រឹត្តិការណ៍ ដែលត្រូវតែកើត
មាន ក្នុងពេលឆាប់ៗខាងមុខនេះ ឲ្យពួកអ្នក
បម្រើរបស់ព្រះអង្គដឹង។ ព្រះយេស៊ូបានចាត់
ទេវទូត*របស់ព្រះអង្គ ឲ្យមកប្រាប់លោកយ៉ូ
ហាន ជាអ្នកបម្រើរបស់ព្រះអង្គ ២លោកយ៉ូ
ហានបានធ្វើជាបន្ទាល់ អំពីហេតុការណ៍ទាំង
ប៉ុន្មាន ដែលលោកបានឃើញ គឺជាព្រះបន្ទូល
របស់ព្រះជាម្ចាស់ និងជាសក្ខីភាពរបស់ព្រះ
យេស៊ូគ្រីស្ត។
៣អ្នកណាអានសៀវភៅនេះ អ្នកនោះមាន
សុភមង្គល*ហើយ! អស់អ្នកដែលស្ដាប់ពាក្យ
លោកថ្លែងក្នុងនាមព្រះជាម្ចាស់ ហើយប្រតិបត្តិ
តាមសេចក្ដីទាំងប៉ុន្មាន ដែលមានចែងទុកមក
នេះ ក៏មានសុភមង្គលដែរ! ដ្បិតពេលកំណត់
ជិតមកដល់ហើយ។

## ពាក្យជម្រាបសួរ

៤ខ្ញុំយ៉ូហាន សូមជម្រាបមកព្រះសហគមន៍
ទាំងប្រាំពីរនៅស្រុកអាស៊ី។ សូមព្រះអង្គដែល
មានព្រះជន្មគង់នៅសព្វថ្ងៃ គង់នៅពីដើម
ហើយកំពុងតែយាងមក មេត្តាប្រណីសន្ដោស
និងប្រទានសេចក្ដីសុខសាន្តដល់បងប្អូន។ សូម
ព្រះវិញ្ញាណទាំងប្រាំពីរ ដែលស្ថិតនៅមុខបល្ល័ង្ក
របស់ព្រះជាម្ចាស់ ៥និងព្រះយេស៊ូគ្រីស្តប្រណី
សន្ដោស ព្រមទាំងប្រទានសេចក្ដីសុខសាន្ត
ដល់បងប្អូនដែរ! ព្រះយេស៊ូជាបន្ទាល់ដ៏ស្មោះ
ត្រង់ ព្រះអង្គមានព្រះជន្មរស់ឡើងវិញមុនគេ
បង្អស់ ហើយព្រះអង្គជាអធិបតីលើស្ដេចទាំង
អស់នៅផែនដី។

ព្រះអង្គមានព្រះហឫទ័យ ស្រឡាញ់យើង
និងបានរំដោះយើងឲ្យរួចពីបាបដោយសារព្រះ
លោហិតរបស់ព្រះអង្គផ្ទាល់។ ៦ព្រះអង្គបានធ្វើ
ឲ្យយើងទៅជារាជាណាចក្រ និងជាក្រុមបូជាចា
រ្យ*បម្រើព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះអ
ង្គ។ សូមលើកតម្កើងសិរីរុងរឿង និងព្រះចេស្ដា
របស់ ព្រះអង្គអស់កល្បជាអង្វែងតរៀងទៅ! អា
ម៉ែន!។ ៧មើល៍! ព្រះអង្គយាងមកនៅកណ្ដាល
ពពក*។ មនុស្សទាំងអស់នឹងឃើញព្រះអង្គ សូ
ម្បីតែអស់អ្នកដែលបានចាក់ទម្លុះព្រះអង្គ ក៏នឹង
ឃើញព្រះអង្គដែរ។ កុលសម្ព័ន្ធទាំងប៉ុន្មាននៅ
លើផែនដី នឹងត្រូវសោកសៅព្រោះតែព្រះអង្គ
[ក]។ មែន!ពិតជាកើតមានដូច្នេះមែន! អាម៉ែន!
។ ៨ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅសព្វ
ថ្ងៃគង់នៅពីដើម ហើយកំពុងតែយាងមក គឺព្រះ
ដ៏មានព្រះចេស្ដាលើអ្វីៗទាំងអស់ ទ្រង់មានព្រះ
បន្ទូលថា៖«យើងជាអាល់ផា និង ជាអូមេកា»

[ខ]។

## លោកយ៉ូហាននិមិត្តឃើញព្រះយេស៊ូ

៩ខ្ញុំយ៉ូហានជាបងប្អូនរបស់អ្នករាល់គ្នា។ ខ្ញុំ
រងទុក្ខលំបាកទទួលព្រះរាជ្យ* និងព្យាយាមរួម
ជាមួយបងប្អូនក្នុងអង្គព្រះយេស៊ូដែរ។ គេបាន
និរទេសខ្ញុំទៅកោះមួយ ឈ្មោះប៉ាតម៉ុស ព្រោះ
តែព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងសក្ខីភាព
របស់ព្រះយេស៊ូ។ ១០នៅថ្ងៃរបស់ព្រះអម្ចាស់[គ]
ព្រះវិញ្ញាណបានធ្វើឲ្យខ្ញុំលង់ស្មារតី ហើយខ្ញុំក៏ឮ
សំឡេងមួយនៅខាងក្រោយខ្ញុំ លាន់រំពងឡើង
យ៉ាងខ្លាំង ដូចសំឡេងត្រែ ១១សំឡេងនោះ
ប្រាប់ថា «អ្វីៗដែលអ្នកបានឃើញត្រូវសរសេរ
ទុកក្នុងសៀវភៅមួយ រួចផ្ញើទៅជូនព្រះសហគម
ន៍ទាំងប្រាំពីរ នៅក្រុងអេភេសូ ក្រុងស្មៀរណា
ក្រុងពែរកាំ ក្រុងធីយ៉ាទេរ ក្រុងសារដែស ក្រុង
ភីឡាដែលភី និង ក្រុងឡៅឌីសេ»។

១២ខ្ញុំក៏ងាកទៅរកសំឡេង ដែលពោលមក
កាន់ខ្ញុំពេលនោះ ខ្ញុំឃើញជើងចង្កៀងមាសប្រាំ
ពីរ។ ១៣នៅកណ្ដាលជើងចង្កៀងទាំងនោះ
មានម្នាក់រាងដូចបុត្រមនុស្ស* ពាក់អាវបំពង់
យ៉ាងវែង ហើយមានខ្សែក្រវាត់មាសនៅដើម
ទ្រូងផង។ ១៤សក់[ឃ]លោកសក្បុសដូចកប្បាស
និងដូចសំឡី[ង] ភ្នែកលោកភ្លឺដូចអណ្ដាតភ្លើង
១៥ជើងលោករលើបដូចលង្ហិន ដែលគេដុតក្នុង
ភ្លើង ហើយសំឡេងលោកឮសូរសន្ធឹកដូចមហា
សាគរ។ ១៦លោកកាន់ផ្កាយប្រាំពីរនៅដៃស្ដាំ
មានដាវដ៏ស្រួចមុខពីរ ចេញពីមាត់របស់លោក
ហើយមុខលោកប្រៀបបីដូចជាថ្ងៃពេញកម្ដៅ។

១៧ពេលខ្ញុំឃើញលោក ខ្ញុំដួលសន្លប់បាត់
ស្មារតី នៅទៀបជើងលោក។ លោកដាក់ដៃស្ដាំ
លើខ្ញុំទាំងពោលថា «កុំខ្លាចអី! គឺយើងនេះ
ហើយដែលនៅមុនគេ និងនៅក្រោយគេបំផុត
១៨យើងបានស្លាប់ តែឥឡូវនេះ យើងមានជីវិត
រស់អស់កល្បជាអង្វែងតរៀងទៅ។ យើងមាន
អំណាចលើសេចក្ដីស្លាប់និងលើស្ថានមច្ចុរាជ
[ច]។ ១៩ដូច្នេះ ចូរកត់ត្រាទុកនូវហេតុការណ៍ទាំង
ប៉ុន្មានដែលអ្នកបានឃើញ គឺហេតុការណ៍ដែល
កំពុងតែកើតមាននៅពេលនេះ និងពេលខាងមុ
ខ។ ២០ចំពោះអត្ថន័យលាក់កំបាំងអំពីផ្កាយទាំង
ប្រាំពីរដែលអ្នកឃើញយើងកាន់នៅដៃ និងជើង
ចង្កៀងមាសទាំងប្រាំពីរនេះ មានដូចតទៅ៖
ផ្កាយទាំងប្រាំពីរ គឺជាទេវទូតរបស់ព្រះសហគម
ន៍*ទាំងប្រាំពីរ ហើយជើងចង្កៀងទាំងប្រាំពីរ គឺ
ជាព្រះសហគមន៍ទាំងប្រាំពីរនោះឯង»។

## លិខិតផ្ញើជូនព្រះសហគមន៍នៅក្រុងអេភេសូ

២ ១«ចូរសរសេរទៅកាន់ទេវទូត*របស់ព្រះ
សហគមន៍ នៅក្រុងអេភេសូ ដូចតទៅ៖
ព្រះអង្គដែលកាន់ផ្កាយទាំងប្រាំពីរ នៅព្រះ
ហស្ដស្ដាំ ហើយដែលយាងនៅកណ្ដាលជើង
ចង្កៀងមាសទាំងប្រាំពីរ ទ្រង់មានព្រះបន្ទូលថា
៖ ២"យើងស្គាល់កិច្ចការដែលអ្នកប្រព្រឹត្ត
ហើយក៏ស្គាល់ការនឿយហត់ និងការព្យាយាម
របស់អ្នកដែរ។ យើងដឹងហើយថា អ្នកមិនអាច
ទ្រាំទ្រ នឹងមនុស្សអាក្រក់បានឡើយអ្នកបាន
ល្បងលមើលពួកដែលតាំងខ្លួន ជាគ្រីស្ដទូត*

ហើយឃើញថាពួកនោះមិនមែនជាគ្រីស្ដទូតទេ
គឺជាអ្នកកុហក។ ៣អ្នកមានចិត្តព្យាយាមអ្នក
បានរងទុក្ខលំបាក ព្រោះតែនាមយើងឥតបាក់
ទឹកចិត្តសោះឡើយ។ ៤ក៏ប៉ុន្តែយើងប្រកាន់អ្នក
ត្រង់កន្លែងមួយ គឺអ្នកលែងមានចិត្តស្រឡាញ់
ដូចអ្នកមានកាលពីដើមដំបូង។ ៥ដូច្នេះ ចូរនឹក
គិតឡើងវិញថា តើអ្នកបានធ្លាក់ចុះពីណាមក
ចូរកែប្រែចិត្តគំនិត ហើយប្រព្រឹត្តអំពើដែលអ្នក
ធ្លាប់ប្រព្រឹត្ត កាលពីដើមនោះឡើងវិញ។ បើពុំ
នោះទេ យើងនឹងមករកអ្នកហើយ បើអ្នកមិនកែ
ប្រែចិត្តគំនិតទេនោះ យើងនឹងយកជើងចង្កៀង
របស់អ្នកចេញពីកន្លែងវាជាមិនខាន។ ៦ក៏ប៉ុន្តែ
យើងសរសើរអ្នកត្រង់កន្លែងមួយ គឺអ្នកស្អប់
អំពើដែលពួកនីកូឡាស[ឆ]ប្រព្រឹត្ត យើងក៏ស្អប់
អំពើទាំងនោះដែរ។

៧ចូរផ្ទៀងត្រចៀកស្ដាប់សេចក្ដី ដែលព្រះ
វិញ្ញាណមានព្រះបន្ទូល មកកាន់ព្រះសហគមន៍
ទាំងនេះឲ្យមែនទែន!។ អ្នកណាមានជ័យជំនះ
យើងនឹងឲ្យអ្នកនោះបរិភោគផ្លែឈើ ដែលបេះ
ពីដើមនៃជីវិត នៅក្នុងសួនឧទ្យាន[ជ]របស់ព្រះជា
ម្ចាស់"»។

## លិខិតផ្ញើជូនព្រះសហគមន៍នៅក្រុងស្មៀរណា

៨«ចូរសរសេរទៅកាន់ទេវទូត* របស់ព្រះ
សហគមន៍*នៅក្រុងស្មៀរណាដូចតទៅនេះ៖

ព្រះអង្គដែលគង់នៅមុនគេ និងនៅក្រោយ
គេបំផុត គឺព្រះអង្គដែលបានសោយទិវង្គត និង
មានព្រះជន្មរស់ឡើងវិញ ទ្រង់មានព្រះបន្ទូល
ថា៖ ៩"យើងស្គាល់ទុក្ខវេទនារបស់អ្នក ហើយ
និងដឹងថាអ្នកកម្សត់ទុគ៌ត តែតាមពិតអ្នកជាអ្នក
មាន។ យើងក៏ដឹងទៀតថា អស់អ្នកដែលតាំង
ខ្លួនជាសាសន៍យូដាបានប្រមាថមាក់ងាយ អ្នក
តែអ្នកទាំងនោះមិនមែនជាសាសន៍យូដាទេ គឺ
ជាទីប្រជុំរបស់មារ*សាតាំង។ ១០កុំខ្លាចទុក្ខ
លំបាក ដែលអ្នកត្រូវជួបប្រទះនោះឡើយ។
តោងដឹងថាមារ* នឹងចាប់អ្នកខ្លះក្នុងចំណោម
អ្នករាល់គ្នា យកទៅឃុំឃាំងដើម្បីល្បងលមើល
អ្នករាល់គ្នា ហើយអ្នកត្រូវរងទុក្ខវេទនាអស់រយៈ
ពេលដប់ថ្ងៃ។ ចូរមានចិត្តស្មោះត្រង់រហូតដល់
ស្លាប់នោះយើងនឹងប្រគល់ជីវិត មកអ្នកទុកជាម
កុដ។ ១១ចូរផ្ទៀងត្រចៀកស្ដាប់សេចក្ដីដែល
ព្រះវិញ្ញាណ មានព្រះបន្ទូលមកកាន់ព្រះសហ
គមន៍ទាំងនេះឲ្យមែនទែន!។ អ្នកណាមានជ័យ
ជំនះសេចក្ដីស្លាប់ទីពីរ ពុំអាចមកយាយីអ្នក
នោះបានឡើយ"»។

## លិខិតផ្ញើជូនព្រះសហគមន៍នៅក្រុងពែរកាំ

១២«ចូរសរសេរទៅកាន់ទេវទូត* របស់ព្រះ
សហគមន៍* នៅក្រុងពែរកាំ ដូចតទៅនេះ៖

ព្រះអង្គដែលមានដាវដ៏ស្រួចមុខពីរ ទ្រង់
មានព្រះបន្ទូលថា៖ ១៣"យើងស្គាល់កន្លែងអ្នក
រស់នៅហើយ គឺអ្នកស្ថិតនៅត្រង់កន្លែងដែល
មានបល្ល័ង្ករបស់មារ*សាតាំង។ អ្នកនៅតែមាន
ចិត្តស្មោះស្ម័គ្រនឹងយើងជានិច្ច[ឈ] សូម្បីតែនៅ
គ្រា ដែលគេសម្លាប់អន់ទីប៉ាសជាបន្ទាល់ដ៏
ស្មោះត្រង់របស់យើងក៏អ្នកពុំបានលះបង់ចោល

ជំនឿរបស់អ្នកចំពោះយើងដែរ។ គេបាន សម្លាប់គាត់ក្នុងក្រុងរបស់អ្នករាល់គ្នា គឺនៅកន្លែងដែលមារសាតាំងនៅ។ ១៤ក៏ប៉ុន្តែយើងប្រកាន់អ្នកត្រង់ចំណុចខ្លះៗ ព្រោះក្នុងចំណោមអ្នកមានអ្នកខ្លះកាន់តាម សេចក្ដីបង្រៀនរបស់បាឡាម។ បាឡាមនេះបានបង្រៀនបាឡាក់ឲ្យប្រើកលល្បិច ទាក់ទាញជនជាតិអ៊ីស្រាអែលឲ្យបរិភោគសាច់ដែលគេសែនព្រះក្លែងក្លាយ និងឲ្យប្រាសចាកសីលធម៌៣។ ១៥រីឯអ្នកវិញក៏ដូច្នោះដែរ គឺក្នុងចំណោមអ្នកមានអ្នកខ្លះ បានកាន់តាមសេចក្ដីបង្រៀន របស់ពួកនីកូឡាសរបៀបនេះដូចគ្នា។ ១៦ដូច្នេះចូរកែប្រែចិត្តគំនិតឡើង បើពុំនោះទេ យើងនឹងមករកអ្នកក្នុងពេលឆាប់ៗខាងមុខ ហើយយកដាវដែលចេញពីមាត់យើង មកប្រយុទ្ធនឹងអ្នកទាំងនោះទៀតផង។ ១៧ចូរផ្ទៀងត្រចៀកស្ដាប់សេចក្ដី ដែលព្រះវិញ្ញាណមានព្រះបន្ទូល មកកាន់ព្រះសហគមន៍ទាំងនេះឲ្យមែនទែន!។ អ្នកណាមានជ័យជំនះ យើងនឹងឲ្យនំម៉ាណាដ៏លាក់កំបាំង ទៅអ្នកនោះព្រមទាំង ប្រគល់ក្រួសពណ៌សមួយដុំ ឲ្យដែរ នៅលើដុំក្រួសនោះ មានចារឹកឈ្មោះមួយថ្មី ដែលគ្មាននរណាម្នាក់ស្គាល់ឡើយវៀរលែងតែអ្នកដែលបានទទួលនោះចេញ"»។

## លិខិតផ្ញើជូនព្រះសហគមន៍ នៅក្រុងធីយ៉ាទៀរ

១៨«ចូរសរសេរទៅកាន់ទេវទូតរបស់ព្រះសហគមន៍នៅក្រុងធីយ៉ាទៀរ ដូចតទៅនេះ៖

ព្រះបុត្រារបស់ព្រះជាម្ចាស់ គឺព្រះអង្គដែលមានព្រះនេត្រភ្លឺដូចអណ្ដាតភ្លើង និងព្រះបាទាដូចលង្ហិនទ្រង់មានព្រះបន្ទូលថា៖ ១៩"យើងស្គាល់កិច្ចការដែលអ្នកប្រព្រឹត្តនោះហើយ យើងដឹងថា អ្នកមានចិត្តស្រឡាញ់មានជំនឿ ចេះបម្រើអ្នកដទៃ មានចិត្តព្យាយាម។ យើងដឹងទៀតថា អំពើដែលអ្នកប្រព្រឹត្តថ្មីៗនេះ មានចំនួនច្រើនលើសមុនទៅទៀត។ ២០ក៏ប៉ុន្តែយើងប្រកាន់អ្នកត្រង់កន្លែងមួយ គឺអ្នកបណ្ដោយឲ្យនាងយេសាបិលជាស្រី ដែលតាំងខ្លួនជាព្យាការិនី*បង្រៀន និងបញ្ឆោតពួកអ្នកបម្រើរបស់យើងឲ្យវង្វេង ឲ្យប្រាសចាកសីលធម៌ និងបរិភោគសាច់ ដែលគេបានសែនព្រះក្លែងក្លាយ។ ២១យើងបានទុកពេលឲ្យស្ត្រីនោះកែប្រែចិត្តគំនិត តែនាងពុំព្រមកែប្រែចិត្តគំនិតឡើយ នាងនៅតែប្រព្រឹត្ត អំពើប្រាសចាកសីលធម៌ដដែល។ ២២ហេតុនេះយើងនឹងធ្វើឲ្យនាងឈឺដេកលើគ្រែយ៉ាងសែនវេទនា ហើយធ្វើឲ្យពួកអ្នកដែលរួមផិតក្បត់ជាមួយនាងវេទនា ដូចគ្នាដែរ លើកលែងតែគេកែប្រែចិត្ត ឈប់ប្រព្រឹត្តអំពើនោះជាមួយនាងទៀត។ ២៣យើងនឹងប្រហារជីវិតកូនចៅរបស់នាង ហើយពេលនោះព្រះសហគមន៍ទាំងអស់នឹងដឹងថា យើងឈ្វេងយល់ចិត្តថ្លើមរបស់មនុស្ស ហើយយើងផ្ដល់ឲ្យអ្នករាល់គ្នាទទួលផលម្នាក់ៗ តាមអំពើដែលខ្លួនបានប្រព្រឹត្ត។ ២៤ចំពោះអ្នកមួយចំនួនទៀតក្នុងចំណោមអ្នករាល់គ្នានៅក្រុងធីយ៉ាទៀរ ដែលពុំបានជំពាក់ចិត្តនឹងលទ្ធិនោះ ហើយក៏ពុំបានស្គាល់"សេចក្ដីជ្រៅជ្រះរបស់មារសាតាំង" ដូចពាក្យគេនិយាយ យើងសុំប្រាប់អ្នករាល់គ្នាថា យើងនឹងមិនដាក់បន្ទុកអ្វីលើអ្នករាល់គ្នាទៀតទេ

២៥គឺគ្រាន់តែកាន់តាមអ្វីៗ ដែលអ្នករាល់គ្នាមានឲ្យខ្ជាប់ខ្ជួន រហូតដល់ពេលយើងមកដល់ប៉ុណ្ណោះបានហើយ។

២៦អ្នកណាមានជ័យជំនះ ហើយបំពេញកិច្ចការរបស់យើងរហូតដល់ចុងបញ្ចប់ យើងនឹងឲ្យអ្នកនោះមានអំណាច គ្រប់គ្រងលើប្រជាជាតិនានា ២៧គេនឹងដឹកនាំ[ង]ប្រជាជាតិទាំងនោះដោយដំបងដែក ដូចគេកម្ទេចភាជន៍ធ្វើពីដីឥដ្ឋ។ ២៨អ្នកនោះមានអំណាចដូចអំណាចដែលយើងបានទទួលពីព្រះបិតារបស់យើង ហើយយើងនឹងប្រគល់ផ្កាយព្រឹកឲ្យអ្នកនោះ។ ២៩ចូរផ្ទៀងត្រចៀកស្ដាប់សេចក្ដី ដែលព្រះវិញ្ញាណមានព្រះបន្ទូលមកកាន់ព្រះសហគមន៍ទាំងនេះឲ្យមែនទែន!"»។

## លិខិតផ្ញើជូនព្រះសហគមន៍ នៅក្រុងសារដែស

១«ចូរសរសេរទៅកាន់ទេវទូត* របស់ព្រះ
៣សហគមន៍ នៅក្រុងសារដែស ដូចតទៅនេះ៖

ព្រះអង្គ ដែលមានព្រះវិញ្ញាណទាំងប្រាំពីររបស់ព្រះជាម្ចាស់ និងមានផ្កាយទាំងប្រាំពីរ ទ្រង់មានព្រះបន្ទូលថា៖ "យើងស្គាល់កិច្ចការដែលអ្នកប្រព្រឹត្តនោះហើយ អ្នកមានឈ្មោះល្បីថារស់ តែតាមពិតអ្នកស្លាប់ទេតើ!។ ២ចូរភ្ញាក់ស្មារតី! ចូរពង្រឹងអ្វីៗ[ច]ដែលនៅសល់ ហើយហៀបនឹងស្លាប់នោះឲ្យមាំមួនឡើង ដ្បិតយើងឃើញថា អំពើដែលអ្នកបានប្រព្រឹត្ត មិនគ្រប់លក្ខណៈនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់របស់យើងទេ។ ៣ដូច្នេះ ចូរនឹកគិតអំពីរបៀបដែលអ្នកបានទទួលនិងបានឮព្រះបន្ទូល ហើយប្រតិបត្តិតាម រួចកែប្រែចិត្តគំនិតទៅ។ ប្រសិនបើអ្នកមិនភ្ញាក់ស្មារតីទេ យើងនឹងមកដូចចោរចូលលួច គឺអ្នកពុំដឹងថា យើងនឹងមកដល់ថ្មើរណាឡើយ។ ៤ក៏ប៉ុន្តែ នៅក្រុងសារដែសនេះមានអ្នកខ្លះក្នុងចំណោមអ្នក ពុំបានធ្វើឲ្យសម្លៀកបំពាក់ខ្លួនប្រឡាក់ទេ គឺគេនឹងដើរជាមួយយើង ដោយមានសម្លៀកបំពាក់ពណ៌សព្រោះគេសមនឹងស្លៀកពាក់បែបនេះ។

៥ហេតុនេះ អ្នកណាមានជ័យជំនះ អ្នកនោះនឹងមានសម្លៀកបំពាក់ពណ៌ស យើងនឹងមិនលុបឈ្មោះគេចេញពីក្រាំងជីវិតឡើយ ហើយយើងនឹងទទួលស្គាល់ឈ្មោះអ្នកនោះ នៅចំពោះព្រះភ័ក្ត្រព្រះបិតារបស់យើង និងនៅចំពោះមុខពួកទេវទូតរបស់ព្រះអង្គ។ ៦ចូរផ្ទៀងត្រចៀកស្ដាប់សេចក្ដី ដែលព្រះវិញ្ញាណមានព្រះបន្ទូលមកកាន់ព្រះសហគមន៍ទាំងនេះ ឲ្យមែនទែន!"»។

## លិខិតផ្ញើជូនព្រះសហគមន៍ នៅក្រុងភីឡាដែលភី

៧«ចូរសរសេរទៅកាន់ទេវទូតរបស់ព្រះសហគមន៍* នៅក្រុងភីឡាដែលភី ដូចតទៅនេះ៖

ព្រះដ៏វិសុទ្ធព្រះដ៏ពិតប្រាកដ ព្រះអង្គដែលកាន់កូនសោរបស់ស្ដេចដាវីឌ បើព្រះអង្គបើកគ្មាននរណាបិទបាន បើព្រះអង្គបិទគ្មាននរណាបើកបាន[ឆ]ទ្រង់មានព្រះបន្ទូលថា៖ ៨"យើងស្គាល់កិច្ចការ ដែលអ្នកប្រព្រឹត្តនោះហើយមើ

ល៍! យើងបានបើកទ្វារចំហនៅមុខអ្នកហើយ
គ្មាននរណាអាចបិទបានទេ។ អ្នកមានអំណាច
តិចមែន តែអ្នកបានប្រតិបត្តិតាមពាក្យយើង
ហើយមិនបានបដិសេធថា មិនស្គាល់ឈ្មោះ
យើងផង។ ៩យើងនឹងប្រគល់អ្នកខ្លះពីសាលា
ប្រជុំរបស់មារ*សាតាំងមកឲ្យអ្នក។ ពួកគេថា
ខ្លួនជាសាសន៍យូដា តាមពិត គេមិនមែនជា
សាសន៍យូដាទេ គឺគេនិយាយកុហក។យើងនឹង
ឲ្យអ្នកទាំងនោះ មកក្រាបនៅទៀបជើងអ្នកព្រម
ទាំងទទួលស្គាល់ថា យើងពិតជាបានស្រឡាញ់
អ្នកមែន។ ១០ដោយអ្នកបានព្យាយាមប្រតិបត្តិ
តាមពាក្យយើង យើងក៏រក្សាអ្នកឲ្យរួចផុតពីគ្រា
លំបាក ដែលនឹងកើតមានក្នុងពិភពលោក
ទាំងមូល ដើម្បីល្បងលមើលមនុស្សនៅលើ
ផែនដីដែរ។ ១១យើងនឹងមកដល់ក្នុងពេលឆា
ប់ៗ អ្វីៗដែលអ្នកមានចូរកាន់ឲ្យបានខ្ជាប់ខ្ជួន
ដើម្បីកុំឲ្យនរណាដណ្ដើម យកមកុដរបស់អ្នក
បាន។

១២អ្នកណាមានជ័យជំនះយើងតាំងអ្នកនោះ
ឲ្យធ្វើជាសសរមួយ នៅក្នុងព្រះវិហារ*នៃព្រះ
របស់យើង ហើយគេនឹងមិនចាកចេញពីព្រះ
វិហារនេះទៀតឡើយ។ យើងនឹងចារឹកព្រះនាម
នៃព្រះរបស់យើង និងឈ្មោះក្រុងនៃព្រះរបស់
យើងលើអ្នកនោះ គឺក្រុងយេរូសាឡឹមថ្មីដែល
ចុះពីស្ថានបរមសុខ ចុះមកពីព្រះរបស់យើង។
យើងក៏នឹងចារឹកនាមថ្មីរបស់យើង លើអ្នកនោះ
ដែរ។ ១៣ចូរផ្ទៀងត្រចៀកស្ដាប់សេចក្ដីដែល
ព្រះវិញ្ញាណមានព្រះបន្ទូល មកកាន់ព្រះសហ
គមន៍ទាំងនេះឲ្យមែនទែន!"»។

## លិខិតផ្ញើជូនព្រះសហគមន៍ នៅក្រុងឡៅឌីសេ

១៤«ចូរសរសេរទៅកាន់ទេវទូត របស់ព្រះ
សហគមន៍*នៅក្រុងឡៅឌីសេ ដូចតទៅនេះ៖

ព្រះអាម៉ែន[ឈ]ជាបន្ទាល់ដ៏ស្មោះត្រង់ និងពិត
ប្រាកដ ហើយជាដើមកំណើតនៃអ្វីៗទាំងអស់
ដែលព្រះជាម្ចាស់បានបង្កើតមក ទ្រង់មានព្រះ
បន្ទូលថា៖ ១៥"យើងស្គាល់កិច្ចការដែលអ្នក
ប្រព្រឹត្តនោះហើយ គឺអ្នកត្រជាក់ក៏មិនត្រជាក់
ក្ដៅក៏មិនក្ដៅ។ ប្រសិនបើអ្នកពិតជាត្រជាក់ ឬ
ពិតជាក្ដៅនោះប្រសើរជាង! ១៦ដោយអ្នកនៅ
ឧណ្ហៗ ត្រជាក់ក៏មិនត្រជាក់ក្ដៅក៏មិនក្ដៅដូច្នេះ
យើងនឹងខ្ជាក់អ្នកចោលជាមិនខាន ១៧ព្រោះអ្នក
ពោលថា "ខ្ញុំជាអ្នកមាន ខ្ញុំមានស្ដុកស្ដម្ភ ហើយ
ខ្ញុំមិនត្រូវការអ្វីទេ" អ្នកពុំដឹងថា ខ្លួនកំពុងតែ
វេទនារហេមរហាម ក្រតោកយ៉ាកខ្វាក់ភ្នែក
គ្មានសម្លៀកបំពាក់បិទបាំងកាយ នោះឡើយ។
១៨យើងសុំទូន្មានអ្នកឲ្យមករកទិញមាសពីយើង
ជាមាសដែលសម្រាំងនៅក្នុងភ្លើង ដើម្បីឲ្យបាន
ទៅជាអ្នកមាន ហើយទិញសម្លៀកបំពាក់ពណ៌
ស មកស្លៀកពាក់បិទបាំងកេរ្តិ៍ខ្មាសរបស់អ្នក កុំ
ឲ្យនៅខ្លួនទទេដូច្នេះ។ ចូរមករកទិញថ្នាំដាក់
ភ្នែកពីយើងផងដែរ ដើម្បីឲ្យអ្នកមើលឃើញច្បា
ស់។ ១៩យើងស្ដីបន្ទោសនិងប្រដែប្រដៅ
អស់អ្នកដែលយើងស្រឡាញ់។ ដូច្នេះចូរមាន
ចិត្តក្លាហាន ហើយកែប្រែចិត្តគំនិតឡើង!។
២០មើល៍ យើងឈរនៅមាត់ទ្វារ ទាំងគោះទ្វារ
ទៀតផង ប្រសិនបើមានអ្នកណាម្នាក់ឮសំឡេង
យើង ហើយបើកទ្វារឲ្យ យើងនឹងចូលទៅក្នុង

ផ្ទះអ្នកនោះ យើងនឹងបរិភោគរួមជាមួយអ្នក
នោះ[ណ] ហើយអ្នកនោះក៏នឹងបរិភោគរួមជាមួយ
យើងដែរ។

២១អ្នកណាមានជ័យជំនះ យើងនឹងឲ្យ
អង្គុយនៅលើបល្ល័ង្ករួមជាមួយយើង ដូចយើង
មានជ័យជម្នះ ហើយអង្គុយនៅលើបល្ល័ង្ក រួម
ជាមួយព្រះបិតារបស់យើងដែរ»។ ២២ចូរផ្ទៀង
ត្រចៀកស្ដាប់សេចក្ដី ដែលព្រះវិញ្ញាណមាន
ព្រះបន្ទូលមកកាន់ព្រះសហគមន៍ទាំងនេះ ឲ្យ
មែនទែន!"»។

## ពិធីថ្វាយបង្គំព្រះជាម្ចាស់នៅជុំវិញបល្ល័ង្ករបស់ព្រះអង្គនាស្ថានបរមសុខ

១បន្ទាប់មក ខ្ញុំឃើញទ្វារមួយបើកចំហនៅ
ស្ថានបរមសុខ* ហើយសំឡេងដែលខ្ញុំបានឮ
កាលពីមុនដូចស្នូរត្រែ បន្លឺមកកាន់ខ្ញុំថា៖«សូម
ឡើងមកនេះ! យើងនឹងបង្ហាញឲ្យអ្នកឃើញ
ហេតុការណ៍ដែលត្រូវកើតមាន នៅពេលខាង
មុខ»។
២រំពេចនោះ ព្រះវិញ្ញាណបានធ្វើឲ្យខ្ញុំលង់
ស្មារតី។ ខ្ញុំឃើញបល្ល័ង្កមួយនៅស្ថានបរមសុខ
ហើយមានព្រះមួយអង្គគង់នៅលើបល្ល័ង្កនោះ។
៣ព្រះអង្គដែលគង់នៅលើបល្ល័ង្កមើលទៅដូចជា
ត្បូងមណីជោតិរស និងត្បូងទទឹម ហើយមាន
ឆព្វណ្ណរង្សីភ្លឺដូចកែវមរកត ព័ទ្ធជុំវិញបល្ល័ង្កនោះ
ដែរ។ ៤នៅជុំវិញបល្ល័ង្កមានបល្ល័ង្កម្ភៃបួនទៀត
ហើយមានព្រឹទ្ធាចារ្យ*ម្ភៃបួនរូប អង្គុយនៅលើ
បល្ល័ង្កទាំងនោះ ស្លៀកពាក់ពណ៌ស និងពាក់
មកុដមាសផង។

៥មានផ្លេកបន្ទោរ មានសំឡេង ព្រមទាំងផ្គរ
លាន់ចេញពីបល្ល័ង្កនោះមក។ នៅមុខបល្ល័ង្ក
មានចង្កៀងប្រាំពីរកំពុងឆេះយ៉ាងភ្លឺចង្កៀងទាំង
នោះ គឺជាព្រះវិញ្ញាណទាំងប្រាំពីររបស់ព្រះជា
ម្ចាស់។

៦នៅមុខបល្ល័ង្ក មានដូចជាសមុទ្រភ្លឺថ្លាដូច
កែវចរណៃ។

នៅចំកណ្ដាលនិងនៅជុំវិញបល្ល័ង្ក មានសត្វ
មានជីវិតបួនរូបដែលមានភ្នែកពេញខ្លួនទាំងមុខ
ទាំងក្រោយ។ ៧សត្វមានជីវិតទីមួយមានរូបរាង
ស្រដៀងនឹងសឹង្ហ សត្វមានជីវិតទីពីរស្រដៀង
នឹងកូនគោ សត្វមានជីវិតទីបីមានមុខដូច
មនុស្ស សត្វមានជីវិតទីបួនស្រដៀងនឹងឥន្ទ្រី
ដែលកំពុងតែហើរ។ ៨សត្វមានជីវិតទាំងបួន
នោះ មានស្លាបប្រាំមួយ ហើយមានភ្នែកពេញ
ខ្លួន ទាំងខាងក្រៅ ទាំងខាងក្នុងរៀងៗខ្លួន។ គេ
ចេះតែនាំគ្នាស្រែក ឥតឈប់ឈរ ទាំងថ្ងៃទាំង
យប់ថា៖ «ព្រះដ៏វិសុទ្ធ* ព្រះដ៏វិសុទ្ធ ព្រះដ៏
វិសុទ្ធ ព្រះជាអម្ចាស់ទ្រង់មានព្រះចេស្ដាលើអ្វីៗ
ទាំងអស់[ត] ព្រះអង្គមានព្រះជន្មគង់នៅតាំងពី
ដើមរៀងមក ទ្រង់គង់នៅសព្វថ្ងៃ ហើយកំពុង
តែយាងមក!»។

៩ពេលណា សត្វមានជីវិតទាំងនោះលើក
តម្កើងសិរីរុងរឿងព្រះកិត្តិនាម និងអរព្រះគុណ
ព្រះអង្គ ដែលគង់នៅលើបល្ល័ង្ក គឺព្រះអង្គដែល
មានព្រះជន្មគង់នៅ អស់កល្បជាអង្វែងតរៀង
ទៅ។ ១០ព្រឹទ្ធាចារ្យទាំងម្ភៃបួនរូបនាំគ្នាក្រាបចុះ
នៅមុខព្រះអង្គដែលគង់នៅលើបល្ល័ង្ក ហើយ
ថ្វាយបង្គំព្រះអង្គ ដែលមានព្រះជន្មគង់នៅ

អស់កល្បជាអង្វែងតរៀងទៅ ព្រមទាំងដោះ
មកុដរបស់ខ្លួនដាក់នៅមុខបល្ល័ង្ក ហើយពោល
ថា៖ ១១«បពិត្រព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ
ព្រះអង្គសមនឹងទទួលសិរីរុងរឿង ព្រះកិត្តិនាម
និងឫទ្ធានុភាព ដ្បិតព្រះអង្គបានបង្កើតរបស់
សព្វសារពើមក អ្វីៗទាំងអស់សុទ្ធតែកើតមាន
ហើយនៅស្ថិតស្ថេរ ដោយសារព្រះហឫទ័យ
របស់ព្រះអង្គ»។

## ក្រាំងដែលមានបិទត្រាប្រាំពីរនិង កូនចៀមរបស់ព្រះជាម្ចាស់

១បន្ទាប់មក ខ្ញុំឃើញក្រាំងមួយ នៅក្នុងព្រះ
៥ហស្តស្ដាំរបស់ព្រះអង្គ ដែលគង់នៅលើបល្ល័
ង្ក ក្រាំងនោះមានសរសេរអក្សរ ទាំងខាងក្នុង
ទាំងខាងក្រៅ ព្រមទាំងមានបោះត្រាប្រាំពីរបិទ
ភ្ជាប់ពីលើផង។ ២បន្ទាប់មកទៀត ខ្ញុំឃើញទេវ
ទូតដ៏ខ្លាំងពូកែមួយរូប ប្រកាសយ៉ាងខ្លាំងថា៖ «
តើនរណាមានឋានៈសមនឹងបកត្រាចេញ
ហើយបើកក្រាំងនេះបាន?»។ ៣ប៉ុន្តែទោះបីនៅ
ស្ថានសួគ៌ក្ដី នៅលើផែនដី ឬនៅក្រោមដីក្ដី
គ្មាននរណាម្នាក់អាចបើកក្រាំង ឬមើលក្រាំង
នោះបានឡើយ។ ៤ពេលនោះខ្ញុំស្រែកយំយ៉ាង
ខ្លាំង ព្រោះគ្មាននរណាម្នាក់មានឋានៈសមនឹង
បើកក្រាំង ឬមើលក្រាំងនោះបានទេ។ ៥
ស្រាប់តែមានព្រឹទ្ធាចារ្យមួយរូបមានប្រសាសន៍
មកខ្ញុំថា៖ «កុំយំអី! មើលហ្ន៎ សឹង្ហដែលកើតនៅ
ក្នុងកុលសម្ព័ន្ធយូដា ជាពន្លកដុះចេញពីស្ដេចដា
វីឌ ព្រះអង្គមានជ័យជំនះអាចនឹងបកត្រាទាំង
ប្រាំពីរ ហើយបើកក្រាំងបាន»។

៦បន្ទាប់មក ខ្ញុំឃើញកូនចៀមមួយឈរនៅ
ចំកណ្ដាលបល្ល័ង្ក នៅកណ្ដាលសត្វមានជីវិត
ទាំងបួន និងនៅកណ្ដាលពួកព្រឹទ្ធាចារ្យ។ កូន
ចៀម[ច]នោះមើលទៅ ដូចជាគេបានសម្លាប់ធ្វើ
យញ្ញបូជា*រួចហើយ មានស្នែងប្រាំពីរ និងភ្នែក
ប្រាំពីរ ជាព្រះវិញ្ញាណទាំងប្រាំពីររបស់ព្រះជា
ម្ចាស់ ដែលព្រះអង្គចាត់ឲ្យយាងទៅពាសពេញ
លើផែនដី។ ៧កូនចៀមនោះបានយាងមក
ទទួលយកក្រាំងពីព្រះហស្ដស្ដាំ របស់ព្រះអង្គ
ដែលគង់នៅលើបល្ល័ង្ក។

៨កាលកូនចៀម បានទទួលក្រាំងរួចហើយ
សត្វមានជីវិតទាំងបួន និងពួកព្រឹទ្ធាចារ្យទាំងម្ភៃ
បួននាក់នាំគ្នាក្រាបចុះ នៅមុខកូនចៀមម្នាក់ៗ
កាន់ពិណមួយ និងកាន់ពែងមាសពេញទៅ
ដោយគ្រឿងក្រអូប ដែលជាពាក្យអធិស្ឋាន*
របស់ប្រជាជនដ៏វិសុទ្ធ*។ ៩គេនាំគ្នាច្រៀងបទ
ចម្រៀងថ្មីថា៖

*"ព្រះអង្គសមនឹងទទួលក្រាំង*
*ហើយបកត្រាផង*
*ព្រោះទ្រង់ត្រូវគេសម្លាប់ធ្វើយញ្ញបូជា*
*ព្រះអង្គបានលោះមនុស្សពីគ្រប់ពូជ គ្រប់*
*ភាសា គ្រប់ប្រជាជន និងពីគ្រប់ជាតិសាសន៍*
*យកមកថ្វាយព្រះជាម្ចាស់*
*ដោយសារព្រះលោហិតរបស់ព្រះអង្គ។*
១០ *ព្រះអង្គបានធ្វើឲ្យគេទៅជារាជាណាចក្រ*
*និង ជាក្រុមបូជាចារ្យ**
*បម្រើព្រះជាម្ចាស់របស់យើង*
*ហើយអ្នកទាំងនោះនឹងគ្រងរាជ្យលើផែនដី"។*

១១ពេលនោះ ខ្ញុំមើលទៅ ហើយឮសូរ

សំឡេងទេវទូត*យ៉ាងច្រើន នៅជុំវិញបល្ល័ង្កជុំ
វិញសត្វមានជីវិតនិងជុំវិញពួកព្រឹទ្ធាចារ្យ។ ទេវ
ទូតទាំងនោះមានចំនួនរាប់ម៉ឺន រាប់សែនច្រើន
អនេកអនន្ត ១២នាំគ្នាបន្លឺសំឡេងឡើងយ៉ាង
ខ្លាំងៗថា «កូនចៀមដែលគេសម្លាប់ធ្វើយញ្ញ
បូជា ទ្រង់សមនឹងទទួលឫទ្ធានុភាពរាជសម្បត្តិ
ព្រះប្រាជ្ញាញាណ ឥទ្ធិឫទ្ធិព្រះកិត្តិនាមសិរី
រុងរឿង និងការសរសើរតម្កើង»។

១៣ពេលនោះ ខ្ញុំឮសត្វលោកទាំងប៉ុន្មាន
នៅស្ថានសួគ៌នៅលើផែនដី នៅក្រោមដីនៅក្នុង
សមុទ្រ ព្រមទាំងអ្វីៗទាំងអស់ដែលនៅស្ថាន
ទាំងនោះបន្លឺសំឡេងឡើងថា៖ «សូមព្រះអង្គ
ដែលគង់លើបល្ល័ង្ក និងកូនចៀមទទួលពាក្យ
សរសើរតម្កើងព្រះកិត្តិនាម សិរីរុងរឿង និងព្រះ
ចេស្ដាអស់កល្បជាអង្វែងតរៀងទៅ!»។

១៤បន្ទាប់មកសត្វមានជីវិតទាំងបួនពោល
ឡើងថា «អាម៉ែន!»ហើយព្រឹទ្ធាចារ្យក៏នាំគ្នា
ក្រាបថ្វាយបង្គំ។

## កូនចៀមបកត្រាប្រាំមួយ

១ខ្ញុំមើលទៅ ឃើញកូនចៀមបកត្រាទីមួយ
៦ក្នុងចំណោមត្រាទាំងប្រាំពីរនោះហើយ ខ្ញុំឮ
សត្វមានជីវិតមួយរូប ក្នុងបណ្ដាសត្វមានជីវិត
ទាំងបួនបន្លឺសំឡេងឡើង ដូចផ្គរលាន់ថា៖«
សូមអញ្ជើញមក!»។ ២ខ្ញុំមើលទៅឃើញសេះ
សមួយ អ្នកជិះសេះនោះកាន់ធ្នូ។ គាត់បាន
ទទួលមកុដមួយ ហើយចាកចេញទៅមានរាង
ដូចជាអ្នកឈ្នះ ដើម្បីវាយយកជ័យជម្នះ។
៣ពេលកូនចៀមបកត្រាទីពីរ ខ្ញុំឮសូរសត្វ
មានជីវិតទីពីរពោលថា៖«សូមអញ្ជើញមក!»។
៤ស្រាប់តែ សេះមួយទៀតចេញមក សម្បុរ
ក្រហមដូចភ្លើង។ អ្នកជិះសេះនោះបានទទួល
អំណាច ដកសន្តិភាពចេញពីផែនដី ដើម្បីឲ្យ
មនុស្សលោក ប្រហារជីវិតគ្នាទៅវិញទៅមក។
គាត់បានទទួលដាវមួយយ៉ាងធំ។

៥ពេលកូនចៀមបកត្រាទីបី ខ្ញុំឮសូរសត្វ
មានជីវិតទីបីពោលថា៖ «សូមអញ្ជើញមក!»។
ខ្ញុំមើលទៅឃើញសេះខ្មៅមួយ។ អ្នកជិះសេះ
នោះកាន់ជញ្ជីងមួយនៅដៃ ៦ហើយខ្ញុំបានឮដូច
ជាមានសំឡេងមួយ ចេញពីក្នុងចំណោមសត្វ
មានជីវិតទាំងបួនថា៖ «អង្ករមួយគីឡូថ្លៃមួយ
ដួង* ពោតបីគីឡូក៏ថ្លៃមួយដួងដែរ[ទ] រីឯប្រេង
និងស្រាទំពាំងបាយជូរវិញ កុំប៉ះពាល់ឲ្យ
សោះ»។

៧ពេលកូនចៀមបកត្រាទីបួន ខ្ញុំឮសូរ
សំឡេងសត្វមានជីវិតទីបួន ពោលថា៖«សូម
អញ្ជើញមក!»។ ៨ខ្ញុំមើលទៅឃើញសេះមួយ
សម្បុរព្រឿងចេក អ្នកជិះសេះនោះឈ្មោះមច្ចុរាជ
ហើយស្ថានមច្ចុរាជ[ផ] ក៏មកជាមួយគាត់ដែរ។មច្ចុ
រាជនិង ស្ថានមច្ចុរាជបានទទួលអំណាចលើមួយ
ភាគបួននៃផែនដី ហើយយកដាវទុរ្ភិក្សជម្ងឺ
អាសន្នរោគ និង សត្វសាហាវនៅលើផែនដី[ន] ឲ្យ
មកប្រល័យជីវិតមនុស្សលោក។

៩ពេលកូនចៀមបកត្រាទីប្រាំ នៅក្រោម
អាសនៈ ខ្ញុំឃើញវិញ្ញាណក្ខន្ធអស់អ្នកដែលគេ
បានប្រហារជីវិត ព្រោះតែព្រះបន្ទូលរបស់ព្រះ
ជាម្ចាស់ និងព្រោះតែអ្នកទាំងនោះបានផ្ដល់
សក្ខីភាព។ ១០អ្នកទាំងនោះស្រែកអង្វរយ៉ាង

ខ្លាំងៗថា៖ «ឱព្រះដ៏ជាចៅហ្វាយព្រះដ៏វិសុទ្ធ*
និងស្មោះត្រង់អើយ! តើពេលណាព្រះអង្គរក
យុត្តិធម៌ និងសងសឹកពួកនៅលើផែនដីដែល
បានបង្ហូរឈាមយើងខ្ញុំ?»។ ១១អ្នកទាំងនោះ
បានទទួលអាវសវែងម្នាក់មួយៗ ហើយឮ
សំឡេងប្រាប់ថាឲ្យនៅរង់ចាំមួយភ្លែតទៀតសិន
ទម្រាំដល់មិត្តរួមការងារ និងបងប្អូនរួមជំនឿ
ឯទៀតៗ ត្រូវគេសម្លាប់ដូចគ្នា គ្រប់ចំនួន។

១២ពេលកូនចៀមបកត្រាទីប្រាំមួយ ខ្ញុំមើល
ទៅឃើញផែនដីរញ្ជួយយ៉ាងខ្លាំង ព្រះអាទិត្យ
បែរជាងងឹតដូចក្រណាត់ខ្មៅ ហើយព្រះច័ន្ទ
ទាំងមូលបែរទៅជាក្រហមដូចឈាម ១៣រីឯ
ផ្កាយនៅលើមេឃ ក៏ធ្លាក់ចុះមកដី ដូចផ្លែល្វាខ្ចី
ជ្រុះ នៅពេលខ្យល់បក់បោកដើមវាយ៉ាងខ្លាំង។
១៤ផ្ទៃមេឃនឹងរសាត់បាត់ទៅ ដូចជាក្រាំងដែល
គេមូរទុក ហើយភ្នំនិងកោះទាំងប៉ុន្មានក៏ត្រូវ
របើកចេញពីកន្លែងរបស់វាដែរ។ ១៥ស្ដេចនានា
នៅលើផែនដី ពួកអ្នកធំ ពួកមេទ័ព ពួកអ្នកមាន
ពួកអ្នកខ្លាំងពូកែពួកអ្នកងារ និងអ្នកជាទាំង
ប៉ុន្មាន ក៏នាំគ្នាទៅពួននៅតាមរអាងភ្នំ និងតាម
ថ្មភ្នំ ១៦ទាំងពោលទៅកាន់ភ្នំនិងថ្មថា៖

*ចូររលំសង្កត់លើយើងខ្ញុំមក*
*ចូរជួយលាក់យើងខ្ញុំ*[ប]
*ឲ្យផុតពីព្រះភក្ត្ររបស់ព្រះអង្គ*
*ដែលគង់នៅលើបល្ល័ង្ក*
*និង ឲ្យផុតពីព្រះពិរោធរបស់កូនចៀម*
១៧ *ដ្បិតថ្ងៃដ៏អស្ចារ្យជាថ្ងៃដែលព្រះអង្គ*
*និងកូនចៀមទ្រង់ព្រះពិរោធនោះ*
*មកដល់ហើយ*
*គ្មាននរណាអាចរួចខ្លួនបានឡើយ។*

## ប្រជារាស្ត្ររបស់ព្រះជាម្ចាស់

១ក្រោយមកទៀត ខ្ញុំឃើញទេវទូត*បួនរូប
៧ឈរនៅទិសទាំងបួននៃផែនដី។ ទេវទូតទាំង
នោះនាំគ្នាទប់ខ្យល់ ទាំងបួនទិស កុំឲ្យបក់បោក
មកលើផែនដី មកលើសមុទ្រ ឬមកលើដើម
ឈើណាមួយឡើយ។ ២បន្ទាប់មក ខ្ញុំឃើញទេវ
ទូតមួយរូបទៀត ឡើងពីទិសខាងកើតមកទាំង
កាន់ត្រារបស់ព្រះ ដ៏មានព្រះជន្មគង់នៅផង។
ទេវទូតនោះបន្លឺសំឡេងយ៉ាងខ្លាំងៗ ទៅកាន់
ទេវទូតទាំងបួន ដែលបានទទួលអំណាចធ្វើទុក្ខ
ទោសផែនដីនិងសមុទ្រថា៖ ៣«សូមកុំអាលធ្វើ
ទុក្ខទោសផែនដី សមុទ្រ ឬដើមឈើណាឡើយ
ចាំយើងបោះត្រាសម្គាល់លើថ្ងាសពួកអ្នកបម្រើ
របស់ព្រះជាម្ចាស់ នៃយើងហើយសិន»។ ៤
ពេលនោះ ខ្ញុំក៏ឮថា អស់អ្នកដែលត្រូវគេបោះ
ត្រាសម្គាល់ មានចំនួនមួយសែនបួនម៉ឺនបួន
ពាន់នាក់ មកពីកុលសម្ព័ន្ធទាំងប៉ុន្មានរបស់ជន
ជាតិអ៊ីស្រាអែលគឺ ៥មានត្រាសម្គាល់មួយម៉ឺន
ពីរពាន់នាក់ ពីកុលសម្ព័ន្ធយូដាមួយម៉ឺនពីរពាន់
នាក់ពីកុលសម្ព័ន្ធរូបេនមួយម៉ឺនពីរពាន់នាក់ពី
កុលសម្ព័ន្ធកាដ ៦មួយម៉ឺនពីរពាន់នាក់ពី
កុលសម្ព័ន្ធអេស៊ែរ មួយម៉ឺនពីរពាន់នាក់ពី
កុលសម្ព័ន្ធណែបថាលី មួយម៉ឺនពីរពាន់នាក់ពី
កុលសម្ព័ន្ធម៉ាណាសេ ៧មួយម៉ឺនពីរពាន់នាក់ពី
កុលសម្ព័ន្ធស៊ីម៉ូន មួយម៉ឺនពីរពាន់នាក់ពីកុលស
ម្ព័ន្ធលេវី មួយម៉ឺនពីរពាន់នាក់ពីកុលសម្ព័ន្ធអ៊ីសា
កា ៨មួយម៉ឺនពីរពាន់នាក់ពីកុលសម្ព័ន្ធសាប៊ូឡូន
មួយម៉ឺនពីរពាន់នាក់ពីកុលសម្ព័ន្ធយ៉ូសែប និង

មួយម៉ឺនពីរពាន់នាក់ពីកុលសម្ព័ន្ធបេនយ៉ាមីន
ដែលគេបានបោះត្រាសម្គាល់។

## ប្រជាជនដ៏ច្រើនកុះករនៅមុខបល្ល័ង្ក

៩ក្រោយមកទៀត ខ្ញុំមើលទៅឃើញមហា
ជនដ៏ច្រើនកុះករ គ្មាននរណាអាចរាប់ចំនួនបាន
ឡើយ អ្នកទាំងនោះមកពីគ្រប់ជាតិសាសន៍គ្រប់
កុលសម្ព័ន្ធ គ្រប់ប្រជាជន និងពីគ្រប់ភាសា។
ពួកគេពាក់អាវសវែង ឈរនៅមុខបល្ល័ង្ក និង
នៅមុខកូនចៀមទាំងកាន់ធាងទន្សែនៅដៃផង។
១០គេនាំគ្នាបន្លឺសំឡេងឡើង យ៉ាងខ្លាំងៗថា៖ «
មានតែព្រះនៃយើងដែលគង់នៅលើបល្ល័ង្កនិង
កូនចៀមប៉ុណ្ណោះទេ ដែលសង្គ្រោះយើង»។
១១ពេលនោះ ទេវទូតទាំងប៉ុន្មានដែលឈរនៅជុំ
វិញបល្ល័ង្ក ជុំវិញពួកព្រឹទ្ធាចារ្យ និងជុំវិញសត្វ
មានជីវិតទាំងបួននាំគ្នាក្រាបនៅមុខបល្ល័ង្ក ទាំង
អោនមុខដល់ដីថ្វាយបង្គំព្រះជាម្ចាស់ ១២ហើយ
ពោលថា៖ «អាម៉ែន! សូមកោតសរសើរសូម
លើកតម្កើងសិរីរុងរឿងព្រះប្រាជ្ញាញាណ សូម
អរព្រះគុណ សូមលើកតម្កើងព្រះកិត្តិនាម
ឫទ្ធានុភាព និងឥទ្ធិឫទ្ធិរបស់ព្រះនៃយើងអស់
កល្បជាអង្វែងតរៀងទៅ! អាម៉ែន!។

១៣ព្រឹទ្ធាចារ្យមួយរូបមានប្រសាសន៍ សួរខ្ញុំ
ថា៖ «តើអស់អ្នកដែលពាក់អាវសវែងនោះជា
នរណាហើយគេមកពីណា?»។ ១៤ខ្ញុំក៏ជម្រាប
លោកថា៖ «លោកម្ចាស់ខ្ញុំអើយលោកទេតើ
ដែលជ្រាប»។ លោកក៏ប្រាប់ខ្ញុំថា៖«ពួកគេ
សុទ្ធតែជាអ្នក ដែលបានឆ្លងកាត់ទុក្ខវេទនាដ៏
ខ្លាំងនោះ។ គេបានបោកអាវរបស់ខ្លួនឲ្យបាន
សស្អាត ក្នុងព្រះលោហិតរបស់កូនចៀម។
១៥ហេតុនេះហើយ បានជាពួកគេស្ថិតនៅមុខប
ល្ល័ង្ករបស់ព្រះជាម្ចាស់ និងគោរពបម្រើព្រះអង្គ
ទាំងថ្ងៃទាំងយប់ នៅក្នុងព្រះវិហាររបស់ព្រះអ
ង្គ។ ព្រះអង្គដែលគង់នៅលើបល្ល័ង្កនឹងទទួល
គេ ឲ្យជ្រកកោនក្នុងព្រះពន្លា*របស់ព្រះអង្គ[ផ]។
១៦ពួកគេនឹងលែងឃ្លាន លែងស្រេកទៀត
ហើយ ព្រះអាទិត្យនិងកម្ដៅគ្រប់យ៉ាងក៏នឹង
លែងធ្វើទុក្ខគេទៀតដែរ[ព] ១៧ដ្បិតកូនចៀម
ដែលគង់នៅកណ្ដាលបល្ល័ង្ក ទ្រង់នឹងឃ្វាលពួក
គេ ព្រះអង្គនឹងនាំគេទៅរកប្រភពទឹកដែលផ្ដល់
ជីវិត ហើយព្រះជាម្ចាស់នឹងជូតទឹកភ្នែកចេញ
អស់ពីភ្នែករបស់គេ[ភ]។

## កូនចៀមបកត្រាទីប្រាំពីរ

១ពេលកូនចៀមបកត្រាទីប្រាំពីរ ស្រាប់តែ
ផ្ទៃមេឃស្ងប់អស់រយៈពេល ប្រមាណជាកន្លះ
ម៉ោង ២ខ្ញុំក៏បានឃើញទេវទូត*ប្រាំពីររូបដែល
ឈរនៅខាងមុខព្រះជាម្ចាស់ ទទួលត្រែប្រាំពី
រ។៣មានទេវទូត*មួយរូបទៀត មកឈរនៅជិត
អាសនៈ* ទាំងកាន់ពានមាសមួយផង។ ទេវ
ទូតនោះ បានទទួលគ្រឿងក្រអូបជាច្រើន យក
ទៅថ្វាយ ជាមួយពាក្យអធិស្ឋានរបស់ប្រជាជន
ដ៏វិសុទ្ធទាំងអស់ នៅលើអាសនៈមាសដែល
ស្ថិតនៅខាងមុខបល្ល័ង្ក។ ៤ផ្សែងគ្រឿងក្រអូប
នោះក៏ហុយចេញពីដៃទេវទូត ឡើងទៅលើ
ជាមួយពាក្យអធិស្ឋានរបស់ប្រជាជន ដ៏វិសុទ្ធ
នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់។ ៥ទេវ
ទូតបានយកពាន ហើយយកភ្លើងពីអាសនៈមក
ដាក់ពេញពាននោះ រួចចាក់ទៅលើផែនដី

ស្រាប់តែមានផ្គរលាន់ មានសំឡេង មានផ្លេក
បន្ទោរ ព្រមទាំងមានរញ្ជួយផែនដីផង។

## សំឡេងត្រែទាំងប្រាំមួយ

៦ទេវទូតទាំងប្រាំពីរដែលកាន់ត្រែទាំង
ប្រាំពីរនោះប្រុងប្រៀបផ្លុំ។

៧ទេវទូតទីមួយផ្លុំត្រែឡើង ស្រាប់តែមាន
ព្រឹលនិងភ្លើងលាយជាមួយឈាម ធ្លាក់មកលើ
ផែនដី ផែនដីក៏ឆេះអស់មួយភាគបី ដើមឈើក៏
ឆេះអស់មួយភាគបី ហើយស្មៅខៀវខ្ចីទាំង
ប៉ុន្មានក៏ឆេះអស់ដែរ។

៨ទេវទូតទីពីរផ្លុំត្រែឡើង ស្រាប់តែមានដូច
ជាភ្នំមួយយ៉ាងធំ ដែលកំពុងតែឆេះធ្លាក់ទៅក្នុង
សមុទ្រ ទឹកសមុទ្រមួយភាគបីក៏ក្លាយទៅជា
ឈាម ៩សត្វទាំងឡាយដែលមានជីវិតរស់នៅ
ក្នុងសមុទ្រត្រូវស្លាប់អស់មួយភាគបីហើយនាវា
ក៏ត្រូវវិនាសបង់អស់មួយភាគបីដែរ។

១០ទេវទូតទីបីផ្លុំត្រែឡើង ស្រាប់តែមាន
ផ្កាយមួយយ៉ាងធំ ដែលកំពុងតែឆេះដូចចន្លុះ
ធ្លាក់ពីលើមេឃមក។ ផ្កាយនោះធ្លាក់មកក្នុង
ទន្លេទាំងឡាយអស់មួយភាគបី ហើយក៏ធ្លាក់
មកលើប្រភពទឹកនានាដែរ។ ១១ផ្កាយនោះមាន
ឈ្មោះថា «ផ្លែស្លែង»ទឹកមួយភាគបីបានក្លាយ
ទៅជាពុល បណ្ដាលឲ្យមនុស្សជាច្រើនស្លាប់
ព្រោះតែជាតិល្វីងរបស់ទឹកទាំងនោះ។

១២ទេវទូតទីបួនផ្លុំត្រែឡើង ស្រាប់តែព្រះ
អាទិត្យបាត់រស្មីអស់មួយភាគបី ហើយព្រះច័ន្ទ
និងផ្កាយក៏បាត់រស្មីមួយភាគបីដែរ ធ្វើឲ្យងងឹត
អស់មួយភាគបី គឺពេលថ្ងៃនឹងងងឹតអស់មួយ
ភាគបី ហើយពេលយប់ក៏នឹងងងឹតអស់មួយ
ភាគបីដែរ។

១៣ពេលនោះ ខ្ញុំមើលទៅហើយឮសូរសត្វ
ឥន្ទ្រីមួយហើរកាត់អាកាសវេហាស៍ ទាំងស្រែក
ឡើងយ៉ាងខ្លាំងៗថា៖ «វេទនាហើយ! វេទនា
ហើយ! មនុស្សនៅលើផែនដីនឹងត្រូវវេទនា
ហើយ ព្រោះតែសំឡេងត្រែឯទៀតៗ ដែលទេវ
ទូតទាំងបីរូបហៀបនឹងផ្លុំ!»។

១ទេវទូត*ទីប្រាំផ្លុំត្រែឡើង ខ្ញុំក៏ឃើញផ្កាយ
៩មួយធ្លាក់ចុះពីលើមេឃ មកផែនដីផ្កាយនោះ
ទទួលកូនសោរណ្ដៅនរកអវិចី ២ហើយបើកទ្វារ
រណ្ដៅនរកអវិចីនោះ ស្រាប់តែមានផ្សែងហុយ
ឡើងមក ដូចផ្សែងដែលហុយចេញពីឡមួយ
យ៉ាងធំ។ ពេលនោះព្រះអាទិត្យនិងលំហ
អាកាសប្រែទៅជាងងឹត ព្រោះតែផ្សែងដែល
ហុយចេញពីរណ្ដៅ។ ៣មានកណ្ដូបជាច្រើន
ចេញពីផ្សែងនោះ ហើរមកលើផែនដីវាបាន
ទទួលអំណាចដូចខ្យាដំរីដែរ។ ៤កណ្ដូបទាំង
នោះបានទទួលបម្រាម មិនឲ្យបំផ្លាញតិណជាតិ
នានាលើផែនដី រុក្ខជាតិ ឬដើមឈើណាមួយ
ឡើយ ត្រូវបំផ្លាញតែមនុស្សណាដែលគ្មានត្រា
របស់ព្រះជាម្ចាស់ បោះសម្គាល់នៅលើថ្ងាស
ប៉ុណ្ណោះ។៥កណ្ដូបទាំងនោះពុំបានទទួលសិទ្ធិ
សម្លាប់ទេ គឺគ្រាន់តែធ្វើឲ្យមនុស្សឈឺចុកចាប់
ក្នុងរវាងប្រាំខែប៉ុណ្ណោះ កណ្ដូបនឹងធ្វើឲ្យមនុស្ស
ឈឺចុកចាប់ដូចខ្យាដំរីទិចដែរ។ ៦នៅគ្រានោះ
មនុស្សរកសេចក្ដីស្លាប់ តែរកមិនឃើញគេចង់
ស្លាប់ណាស់ តែសេចក្ដីស្លាប់រត់ចេញឆ្ងាយពី

គេ។ ៧កណ្ដូបទាំងនោះមានរាងដូចសេះដែលគេបំពាក់គ្រឿងសឹក ចេញទៅច្បាំងនៅលើក្បាល វាមានពាក់កម្រងដូចជាមកុដមាស ហើយមុខវាដូចមុខមនុស្ស។ ៨វាមានសក់វែងដូចសក់ស្ត្រី ហើយមានធ្មេញដូចធ្មេញសឹង្ហ។ ៩វាមានគ្រឿងក្រោះដូចអាវក្រោះធ្វើពីដែក។ ពេលវាហើរ ស្នូរស្លាបរបស់វាលាន់ឮសន្ធឹកដូចរទេះទឹមដោយសេះជាច្រើន បោលទៅធ្វើសឹកសង្គ្រាម។ ១០កន្ទុយរបស់វាមានទ្រនិចដូចខ្យាដំរី ហើយមានអំណាចនឹងឲ្យមនុស្សម្នាឈឺចុកចាប់ អស់រយៈពេលប្រាំខែ។ ១១កណ្ដូបទាំងនោះមានយមរាជ[ម] ធ្វើជាស្ដេចដឹកនាំវា ដែលមានឈ្មោះជាភាសាហេប្រឺថាអាបាដូន ជាភាសាក្រិកថា អាប៉ូលីយ៉ូន។

១២លុះទុក្ខវេទនាទីមួយ បានកន្លងផុតទៅ ទុក្ខវេទនាពីរទៀត ក៏កើតមកតាមក្រោយ។

១៣ទេវទូតទីប្រាំមួយផ្លុំត្រែឡើង ខ្ញុំក៏បានឮសំឡេងមួយចេញពីស្នែងនៅជ្រុងទាំងបួនរបស់អាសនៈមាស ដែលស្ថិតនៅខាងមុខព្រះជាម្ចាស់។ ១៤សំឡេងនោះពោលមកកាន់ទេវទូតទីប្រាំមួយដែលមានត្រែនៅដៃថា៖ «ចូរស្រាយទេវទូតទាំងបួនរូប ដែលជាប់ចំណងនៅលើទន្លេធំ គឺទន្លេអឺប្រាតនោះទៅ!»។ ១៥គេក៏ស្រាយទេវទូតទាំងបួនរូប ដែលបានប្រុងប្រៀបខ្លួនប្រហារជីវិតមនុស្សមួយភាគបីត្រូវតាមម៉ោង ថ្ងៃខែនិងឆ្នាំ។ ១៦ខ្ញុំបានឮថាចំនួនទាហានទ័ពសេះនោះមានទាំងអស់ ពីររយលាននាក់។ ១៧ក្នុងនិមិត្តហេតុអស្ចារ្យ ដែលខ្ញុំបានឃើញនោះមានសេះនិងពលទាហាន ដែលជិះពីលើវាពាក់អាវក្រោះ ពណ៌ក្រហមដូចភ្លើងពណ៌បៃតងខ្ចីនិងពណ៌លឿងដូចស្ពាន់ធ័រ។ រីឯក្បាលសេះវិញមានរាងដូចជាក្បាលសឹង្ហ ហើយមានភ្លើង ផ្សែងនិងស្ពាន់ធ័រ ចេញពីមាត់វាមកផង។ ១៨មនុស្សមួយភាគបីបានស្លាប់ ដោយសារគ្រោះកាចទាំងបីមុខនេះ គឺស្លាប់ដោយភ្លើងដោយផ្សែងនិងដោយស្ពាន់ធ័រដែលចេញពីមាត់សេះ ១៩ដ្បិតអំណាចរបស់សេះទាំងនោះ ស្ថិតនៅលើមាត់និងកន្ទុយ។ កន្ទុយរបស់វាប្រៀបបានទៅនឹងពស់ គឺមានក្បាលហើយវាធ្វើឲ្យមនុស្សវេទនាដោយសារតែក្បាលហ្នឹងឯង។

២០រីឯមនុស្សឯទៀតៗ ដែលមិនបានស្លាប់ដោយគ្រោះកាចទាំងនោះ ពុំព្រមកែប្រែចិត្តគំនិតឈប់ប្រព្រឹត្តអំពើរបស់ខ្លួនទេ គឺគេពុំព្រមឈប់ថ្វាយបង្គំអារក្សថ្វាយបង្គំរូបសំណាករបស់ព្រះក្លែងក្លាយធ្វើពីមាសពីប្រាក់ពីលង្ហិនពីថ្ម និងធ្វើពីឈើជាព្រះដែលមិនចេះមើលមិនចេះស្ដាប់ ហើយក៏មិនចេះដើរនោះឡើយ។ ២១គេក៏ពុំព្រមកែប្រែចិត្តគំនិត ឈប់ប្រព្រឹត្តអំពើឃាតកម្មវិជ្ជាធ្មប់ អំពើប្រាសចាកសីលធម៌ និងអំពើលួចប្លន់ដែលខ្លួនបានប្រព្រឹត្តនោះដែរ។

## ទេវទូតប្រគល់ក្រាំងមួយតូចឲ្យលោកយ៉ូហាន

១ខ្ញុំឃើញទេវទូត* ខ្លាំងពូកែមួយរូបទៀត
១០ចុះពីលើមេឃមកមានពពក* ព័ទ្ធជុំវិញខ្លួន មានឆព្វណ្ណរង្សី នៅលើក្បាលមុខលោកដូចព្រះអាទិត្យ ហើយជើងលោកដូចសសរភ្លើង។ ២ដៃលោកកាន់ក្រាំងតូចមួយ ដែលបើកស្រាប់

លោកដាក់ជើងស្ដាំលើសមុទ្រជើងឆ្វេងលើដី
គោក។ ៣លោកបន្លឺសំឡេងឡើងយ៉ាងខ្លាំង
ដូចសឹង្ហគ្រហឹម ហើយពេលទេវទូតនោះបន្លឺ
សំឡេង ផ្គរទាំងប្រាំពីរ ក៏លាន់ឮឡើងដែរ។
៤ពេលផ្គរលាន់ឮរួចហើយ ខ្ញុំហៀបនឹងសរសេរ
ទុក ស្រាប់តែឮសំឡេងមួយពោលពីលើមេឃ
មកថា៖ «ចូរលាក់សេចក្ដីដែលផ្គរលាន់ទាំង
ប្រាំពីរបានថ្លែងនោះឲ្យជិត កុំសរសេរទុក
ឡើយ»។ ៥រីឯទេវទូតដែលខ្ញុំបានឃើញឈរ
លើសមុទ្រនិងលើដីគោកនោះ ក៏លើកដៃស្ដាំ
ឡើងទៅលើមេឃ ៦ហើយស្បថក្នុងព្រះនាម
ព្រះអង្គដែលមានព្រះជន្មគង់នៅ អស់កល្បជា
អង្វែងតរៀងទៅ[យ] គឺព្រះអង្គដែលបានបង្កើតផ្ទៃ
មេឃ និងអ្វីៗដែលមាននៅលើមេឃ ផែនដីនិង
អ្វីៗដែលមាននៅលើផែនដីសមុទ្រ និងអ្វីៗ
ដែលមាននៅក្នុងសមុទ្រ។ ទេវទូតនោះបាន
ពោលយ៉ាងឱឡារិកថា «គ្មានពន្យារពេលទៀត
ឡើយ ៧នៅគ្រាណាទេវទូតទីប្រាំពីរបន្លឺ
សំឡេងឡើង គឺនៅពេលលោកចាប់ផ្ដើមផ្លុំត្រែ
ព្រះជាម្ចាស់នឹងសម្រេចតាមគម្រោងការដ៏លាក់
កំបាំងរបស់ព្រះអង្គ ដូចទ្រង់បានប្រទានដំណឹង
ល្អទុកជាមុន តាមរយៈពួកព្យាការី*ជាអ្នកបម្រើ
របស់ព្រះអង្គ»។

៨បន្ទាប់មក សំឡេងដែលខ្ញុំបានឮពីលើ
មេឃនោះ ក៏ពោលមកកាន់ខ្ញុំម្ដងទៀតថា៖«
សូមអញ្ជើញទៅយកក្រាំងតូចបើកស្រាប់ ក្នុង
ដៃទេវទូតដែលឈរលើសមុទ្រ និងលើដីគោក
នោះមក»។ ៩ខ្ញុំក៏ដើរទៅរកទេវទូតនោះទាំងសុំ
ឲ្យលោកប្រគល់ក្រាំងតូចមកខ្ញុំ។ លោកពោល
មកកាន់ខ្ញុំថា៖«ចូរយកក្រាំងនេះហើយបរិភោគ
វាទៅ។ ក្រាំងនេះនឹងធ្វើឲ្យអ្នកឈឺពោះ[រ] តែ
កាលនៅក្នុងមាត់វាផ្អែមដូចទឹកឃ្មុំ»។ ១០ខ្ញុំក៏
ទទួលយកក្រាំងតូចពីដៃទេវទូត មកបរិភោគ
នៅក្នុងមាត់ខ្ញុំវាផ្អែមដូចទឹកឃ្មុំ[ល] លុះបរិភោគរួច
ហើយ ខ្ញុំក៏ឈឺពោះ។ ១១បន្ទាប់មក មានគេ
ប្រាប់ខ្ញុំថា៖ «អ្នកត្រូវថ្លែងព្រះបន្ទូលសាជាថ្មី
ទៀត អំពីប្រជាជន អំពីជាតិសាសន៍ អំពីភាសា
នានា និងអំពីស្ដេចជាច្រើនផង»។

## ក្រុងដ៏វិសុទ្ធ និងបន្ទាល់ពីររូប

១បន្ទាប់មក ទេវទូត*បានប្រគល់ដើមត្រែង
១១មួយ មកខ្ញុំស្រដៀងនឹងដំបងសម្រាប់វាស់
ហើយប្រាប់ថា៖ «ចូរក្រោកឡើង ទៅវាស់ព្រះ
វិហារ*របស់ព្រះជាម្ចាស់ វាស់អាសនៈ និងរាប់
អស់អ្នកដែលថ្វាយបង្គំព្រះអង្គ នៅទីនោះផង។
២ក៏ប៉ុន្តែត្រូវទុកទីលាន ដែលនៅខាងក្រៅព្រះ
វិហារដោយឡែក កុំវាស់ឲ្យសោះ ដ្បិតព្រះអង្គ
បានប្រគល់លាននោះ ឲ្យជាតិសាសន៍នានា
ហើយពួកគេនឹងជាន់ឈ្លីក្រុងដ៏វិសុទ្ធអស់រយៈ
ពេលសែសិបពីរខែ។

៣យើងនឹងឲ្យបន្ទាល់របស់យើង ទាំងពីររូប
ស្លៀកបាវ[វ]ទៅថ្លែងព្រះបន្ទូល ក្នុងរយៈពេល
មួយពាន់ពីររយហុកសិបថ្ងៃនោះ។ ៤អ្នកទាំងពីរ
នេះ គឺជាដើមអូលីវទាំងពីរ និងជាជើងចង្កៀង
ទាំងពីរដែល ស្ថិតនៅខាងមុខព្រះអម្ចាស់នៃ
ផែនដី[ស]។ ៥ប្រសិនបើមាននរណាម្នាក់ចង់ធ្វើ
ទុក្ខអ្នកទាំងពីរនោះ នឹងមានភ្លើងចេញពីមាត់
គាត់ មកឆេះបំផ្លាញមារសត្រូវរបស់គាត់ជាមិន
ខាន។ ប្រាកដណាស់ ប្រសិនបើអ្នកណាចង់ធ្វើ
ទុក្ខអ្នកទាំងពីរ អ្នកនោះពិតជាត្រូវស្លាប់បែប

នេះឯង។ ៦អ្នកទាំងពីរមានអំណាចធ្វើឲ្យមេឃ
រាំង គ្មានភ្លៀងធ្លាក់ក្នុងអំឡុងពេលដែលគាត់
ថ្លែងព្រះបន្ទូល ហើយក៏មានអំណាចធ្វើឲ្យទឹក
ក្លាយទៅជាឈាម ព្រមទាំងធ្វើឲ្យគ្រោះកាច
គ្រប់យ៉ាងអាចកើតមាន នៅលើផែនដីពេល
ណាក៏បាន តាមតែគាត់ចង់។

៧ពេលអ្នកទាំងពីរ បានផ្ដល់សក្ខីភាពរបស់
ខ្លួនចប់សព្វគ្រប់ហើយ មានសត្វតិរច្ឆានឡើងពី
នរកអវិចីមកច្បាំងនឹងគេ វានឹងឈ្នះ ហើយ
ប្រហារជីវិតគេទៀតផង។ ៨សាកសពរបស់អ្នក
ទាំងពីរនឹងត្រូវទុកចោលនៅតាមទីផ្សារ ក្នុង
ក្រុងដ៏ធំនោះជាក្រុង ដែលមានឈ្មោះជា
និមិត្តរូបថា "សូដុម" ឬ"អេស៊ីប" គឺនៅក្រុង
នោះហើយ ដែលគេឆ្កាងព្រះអម្ចាស់របស់អ្នក
ទាំងពីរ។ ៩មនុស្សម្នាពីចំណោមប្រជាជននានា
ពីចំណោមកុលសម្ព័ន្ធ ពីចំណោមភាសា និងពី
ចំណោមជាតិសាសន៍ទាំងឡាយ នឹងឃើញ
សាកសពរបស់អ្នកទាំងពីរ ក្នុងរវាងបីថ្ងៃកន្លះ
ហើយពួកគេមិនអនុញ្ញាតឲ្យយកសាកសពអ្នក
ទាំងពីរទៅបញ្ចុះក្នុងផ្នូរឡើយ។ ១០មនុស្សម្នា
ដែលរស់នៅផែនដីនឹងមានចិត្តត្រេកអរ ដោយ
ឃើញអ្នកទាំងពីរស្លាប់គឺគេមានអំណរសប្បាយ
យ៉ាងខ្លាំង។ ពួកគេនឹងផ្ញើជំនូនឲ្យគ្នាទៅវិញទៅ
មក ព្រោះព្យាការី*ទាំងពីររូបបានធ្វើឲ្យមនុស្ស
ម្នាដែលរស់នៅលើផែនដី រងទុក្ខលំបាកខ្លាំង
ណាស់។

១១បីថ្ងៃកន្លះក្រោយមក មានដង្ហើមជីវិត[ហ]
មួយចេញពីព្រះជាម្ចាស់ មកចូលក្នុងសាកសព
អ្នកទាំងពីរ។ អ្នកទាំងពីរក៏ក្រោកឈរឡើងធ្វើ
ឲ្យអស់អ្នកដែលបានឃើញ ភ័យខ្លាចជាខ្លាំង។
១២អ្នកទាំងពីរបានឮសំឡេងមួយពីលើមេឃ
បន្លឺយ៉ាងខ្លាំងមកកាន់គេថា "សូមឡើងមក
នេះ!"។ អ្នកទាំងពីរក៏ឡើងទៅលើមេឃក្នុង
ពពក* រីឯពួកសត្រូវក៏បានឃើញដែរ។ ១៣ខ
ណៈនោះ ស្រាប់តែមានរញ្ជួយផែនដីយ៉ាងខ្លាំង
ក្រុងរលំអស់មួយភាគដប់ មនុស្សប្រាំពីរពាន់
នាក់បានបាត់បង់ជីវិត នៅពេលរញ្ជួយផែនដី។
អ្នកសល់ពីស្លាប់ភ័យញ័ររន្ធត់នាំគ្នាលើកតម្កើង
សិរីរុងរឿង ព្រះជាម្ចាស់នៃស្ថានបរមសុខ*»។

១៤ទុក្ខវេទនាទីពីរនេះបានកន្លងផុតទៅ ទុក្ខ
វេទនាទីបីនឹងមកដល់ក្នុងពេលឆាប់ៗ។

## សំឡេងត្រែទីប្រាំពីរ

១៥ទេវទូត*ទីប្រាំពីរផ្លុំត្រែឡើង ស្រាប់តែ
មានសំឡេងលាន់ឮរំពង នៅលើមេឃថា៖«
រាជ្យក្នុងលោកនេះ ត្រូវផ្ទេរថ្វាយទៅព្រះអម្ចាស់
នៃយើង និងថ្វាយព្រះគ្រីស្ដរបស់ព្រះអង្គ
ហើយទ្រង់នឹងគ្រងរាជ្យអស់កល្បជាអង្វែងត
រៀងទៅ!»។

១៦ពេលនោះ ព្រឹទ្ធាចារ្យ*ទាំងម្ភៃបួនរូប
ដែលអង្គុយលើបល្ល័ង្ក នៅខាងមុខព្រះជាម្ចាស់
ក៏នាំគ្នាក្រាបអោនមុខដល់ដី ហើយថ្វាយបង្គំ
ព្រះជាម្ចាស់ ១៧ទាំងពោលថា៖

*«បពិត្រព្រះជាអម្ចាស់*
*ជាព្រះដ៏មានព្រះចេស្ដាលើអ្វីៗទាំងអស់*
*ព្រះអង្គមានព្រះជន្មគង់នៅសព្វថ្ងៃនេះ*
*ហើយក៏មានព្រះជន្មគង់នៅ*
*តាំងពីដើមរៀងមកដែរ!*

*យើងខ្ញុំសូមអរព្រះគុណព្រះអង្គ*
*ព្រោះទ្រង់បានយកឫទ្ធានុភាពដ៏ខ្លាំងក្លា*
*របស់ព្រះអង្គ*
*មកតាំងព្រះរាជ្យរបស់ព្រះអង្គឡើង។*
១៨ *ជាតិសាសន៍នានាបាននាំគ្នាខឹង*
*ហើយពេលដែលព្រះអង្គសម្តែងព្រះពិរោធ*
*ក៏មកដល់ដែរ*
*គឺជាពេលកំណត់ដែលព្រះអង្គវិនិច្ឆ័យទោស*
*មនុស្សស្លាប់។*
*នៅពេលនោះ ព្រះអង្គនឹងប្រទានរង្វាន់ដល់*
*ពួកព្យាការី* ជាអ្នកបម្រើរបស់ព្រះអង្គ*
*ដល់ប្រជាជនដ៏វិសុទ្ធ**
*និង ដល់អស់អ្នកដែលគោរពកោតខ្លាច*
*ព្រះនាមព្រះអង្គ ទាំងអ្នកតូច ទាំងអ្នកធំ*
*ហើយក៏ជាពេលដែលព្រះអង្គត្រូវបំផ្លាញ*
*អស់អ្នកដែលបានបំផ្លាញផែនដីដែរ»។*

១៩ពេលនោះ ទ្វារព្រះវិហារ*របស់ព្រះជា
ម្ចាស់នៅស្ថានបរមសុខ ក៏បើកចំហឡើងហើយ
ហិបនៃសម្ពន្ធមេត្រី*របស់ព្រះអង្គ ក៏លេចមក
នៅក្នុងព្រះវិហារ ហើយក៏មានផ្លេកបន្ទោរ មាន
ឮសូរសំឡេង មានផ្គរលាន់មានរញ្ជួយផែនដី
និងមានព្រឹលធ្លាក់មកយ៉ាងខ្លាំងផងដែរ។

## ស្ត្រីនិងនាគ

១ពេលនោះ មានទីសម្គាល់មួយយ៉ាងធំ
១២លេចចេញមក នៅលើមេឃ គឺមានស្ត្រីមួយ
រូបស្លៀកពាក់ព្រះអាទិត្យ បិទបាំងកាយមាន
ព្រះច័ន្ទនៅក្រោមជើង ព្រមទាំងមានពាក់ផ្កាយ
ដប់ពីរ ជាមកុដនៅលើក្បាលផង។
២ស្ត្រីនោះ
មានផ្ទៃពោះ ហើយកំពុងស្រែកឈឺចុកចាប់
ហៀបនឹងសម្រាលបុត្រ។
៣មានទីសម្គាល់មួយទៀត លេចចេញមក
នៅលើមេឃដែរ គឺមាននាគមួយយ៉ាងធំ សម្បុរ
ក្រហមឆ្អិនឆ្អៅដូចភ្លើង។ នាគនោះមានក្បាល
ប្រាំពីរ និងមានស្នែងដប់ ហើយនៅលើក្បាល
ទាំងប្រាំពីររបស់វា មានមកុដប្រាំពីរដែរ។
៤កន្ទុយវាកៀរប្រមូលផ្កាយនៅលើមេឃ មួយ
ភាគបីទម្លាក់មកផែនដី។ នាគមកពេននៅមុខ
ស្ត្រីដែលហៀបនឹងសម្រាលបុត្រ ចាំត្របាក់
លេបបុត្រនៅពេលបុត្រនោះកើតមក។
៥នាង
សម្រាលបានបុត្រមួយ ដែលត្រូវកាន់ដំបងដែក
ដឹកនាំជាតិសាសន៍ទាំងអស់[ឡ]។ ក៏ប៉ុន្តែ ព្រះជា
ម្ចាស់បានឆក់យកបុត្រនោះ ឡើងទៅជាមួយ
ព្រះអង្គ គឺនៅជិតបល្ល័ង្ករបស់ព្រះអង្គ។
៦រីឯស្ត្រី
វិញ នាងរត់ភៀសខ្លួនទៅនៅវាលរហោស្ថាន
ត្រង់កន្លែង ដែលព្រះជាម្ចាស់បានរៀបចំទុក
ដើម្បីឲ្យគេទំនុកបម្រុងនាងក្នុងអំឡុងពេលមួយ
ពាន់ពីររយហុកសិបថ្ងៃ។
៧ពេលនោះ ក៏មាន
ចម្បាំងផ្ទុះឡើងនៅលើមេឃ គឺមហាទេវតាមីកា
អែល និងពួកទេវទូតរបស់លោកនាំគ្នាច្បាំងនឹង
នាគ ហើយនាគរួមជាមួយពួកបរិវារវាក៏ច្បាំងត
ទល់វិញដែរ
៨ក៏ប៉ុន្តែវាច្បាំងមិនឈ្នះ ហើយរក
កន្លែងស្នាក់នៅលើមេឃ មិនបានទៀតឡើយ។
៩នាគធំនោះក៏ត្រូវគេទម្លាក់ចុះមក គឺនាគធំហ្នឹង
ឯងជាពស់ពីបុរាណ ឈ្មោះមារ* ឬសាតាំង
ដែលបាននាំមនុស្សនៅលើផែនដីទាំងមូលឲ្យវ
ង្វេង។ វាត្រូវគេទម្លាក់ចុះមកផែនដី ហើយពួក
បរិវារវាក៏ត្រូវគេទម្លាក់ចុះមកជាមួយដែរ។

១០ពេលនោះ ខ្ញុំបានឮសំឡេងមួយបន្លឺយ៉ាង

ខ្លាំងនៅលើមេឃថា៖ «ឥឡូវនេះដល់ពេលព្រះ
ជាម្ចាស់សង្គ្រោះមនុស្សលោកហើយ ហើយ
ឫទ្ធានុភាពនិងព្រះរាជ្យ* ព្រះជាម្ចាស់របស់
យើង ព្រមទាំងអំណាចព្រះគ្រីស្តរបស់ព្រះអង្គ
ក៏បានមកដល់ដែរ ដ្បិតអ្នកចោទប្រកាន់ទោស
បងប្អូនយើងត្រូវគេទម្លាក់ចោលហើយ គឺអ្នក
នោះឯងដែលចោទប្រកាន់បងប្អូនយើង ទាំងថ្ងៃ
ទាំងយប់ នៅមុខព្រះភ័ក្ត្រនៃព្រះរបស់យើង។
១១បងប្អូនយើងបានឈ្នះវា ដោយសារព្រះ
លោហិតរបស់កូនចៀម និងដោយសក្ខីភាព
របស់ពួកគេ ហើយបងប្អូនទាំងនោះបានស៊ូប្ដូរ
ជីវិត ឥតស្ដាយសោះឡើយ។ ១២ហេតុនេះ
ស្ថានបរមសុខ* និងអស់អ្នកដែលរស់នៅក្នុង
ស្ថានបរមសុខអើយ ចូរមានអំណរសប្បាយ
ឡើង! រីឯផែនដីនិងសមុទ្រវិញ អ្នកត្រូវវេទនា
ជាពុំខាន! ដ្បិតមារ*បានចុះទៅរកអ្នករាល់គ្នា
ទាំងមានកំរោលចូលយ៉ាងខ្លាំងផង ព្រោះវាដឹង
ថាវានៅសល់ពេលតែបន្តិចប៉ុណ្ណោះ»។

១៣កាលនាគឃើញថា ខ្លួនត្រូវគេទម្លាក់ចុះ
មកលើផែនដីដូច្នេះ វាក៏ដេញតាមស្ត្រីដែលបាន
សម្រាលបុត្រ។ ១៤នាងបានទទួលស្លាបទាំងពីរ
របស់ឥន្ទ្រីដ៏ធំនោះ ដើម្បីហោះទៅកាន់វាល
រហោស្ថាន គឺនៅកន្លែងរបស់នាង។ នៅទីនោះ
ព្រះជាម្ចាស់នឹងទំនុកបម្រុងនាង ក្នុងរយៈពេល
មួយវស្សាពីរវស្សា និងពាក់កណ្ដាលវស្សា[អ] ឲ្យ
ឆ្ងាយពីមុខពស់។ ១៥ពស់បានព្រួសទឹកចេញពី
មាត់វាដូចទឹកទន្លេតាមពីក្រោយនាង ដើម្បីឲ្យ
ទឹកហូរនាំយកនាងទៅ ១៦ក៏ប៉ុន្តែព្រះធរណីបាន
ជួយនាងដោយស្រូបទឹកទន្លេដែលនាគបាន
ព្រួសចេញពីមាត់វានោះអស់។ ១៧នាគក្ដៅ
ក្រហាយនឹងស្ត្រីនោះយ៉ាងខ្លាំង វាក៏ចេញទៅធ្វើ
សឹកនឹងកូនចៅរបស់នាងដែលនៅសល់ គឺធ្វើ
សឹកនឹងអស់អ្នកដែលប្រតិបត្តិតាមវិន័យ*របស់
ព្រះជាម្ចាស់ និងអស់អ្នកដែលបានជឿសក្ខីភាព
របស់ព្រះយេស៊ូ។

១៨បន្ទាប់មកនាគក៏ទៅនៅតាមឆ្នេរខ្សាច់នា
មាត់សមុទ្រ។

## សត្វតិរច្ឆានដែលចេញពីសមុទ្រ

១បន្ទាប់មកទៀត ខ្ញុំឃើញសត្វតិរច្ឆានមួយ
១៣មានស្នែងដប់ និងក្បាលប្រាំពីរឡើងពីស
មុទ្រមកនៅលើស្នែងទាំងដប់របស់វា មានមកុដ
ដប់ ហើយនៅលើក្បាលទាំងប្រាំពីរ មានសរ
សេរឈ្មោះផ្សេងៗ ដែលប្រមាថព្រះជាម្ចាស់។
២សត្វដែលខ្ញុំឃើញនោះ មានរាងដូចជាខ្លា
រខិន ជើងវាដូចជើងខ្លាឃ្មុំ ហើយមាត់វាដូចមាត់
សឹង្ហ។ នាគបានប្រគល់ឫទ្ធានុភាពនិងបល្ល័ង្ក
របស់វា ព្រមទាំងអំណាចយ៉ាងធំទៅឲ្យសត្វ
នោះ។ ៣ខ្ញុំក៏ឃើញក្បាលមួយរបស់សត្វនោះ
ដូចជាត្រូវរបួសជិតស្លាប់ តែមុខរបួសដ៏ធ្ងន់ជិត
ស្លាប់នេះបានជាសះស្បើយឡើងវិញ។ មនុស្ស
ម្នានៅលើផែនដីទាំងមូល កោតស្ញប់ស្ញែងយ៉ាង
ខ្លាំង ហើយនាំគ្នាទៅតាមសត្វនោះ។ ៤គេនាំគ្នា
ក្រាបថ្វាយបង្គំនាគ ព្រោះនាគបានប្រគល់
អំណាចឲ្យសត្វនោះ ហើយគេក៏ក្រាបថ្វាយបង្គំ
សត្វនោះដែរ ទាំងពោលថា៖ «តើនរណាអាច
ប្រៀបផ្ទឹមនឹងសត្វនេះបាន? តើនរណាអាច
ច្បាំងតទល់នឹងសត្វនេះបាន?»។

៥សត្វនោះបានទទួលសិទ្ធិ ពោលពាក្យ
ព្រហើនៗ ព្រមទាំងប្រមាថព្រះជាម្ចាស់ទៀតផ
ង។ វាបានទទួលអំណាចបញ្ចេញសកម្មភាព
ក្នុងអំឡុងពេលសែសិបពីរខែ។ ៦វាបានហា
មាត់ប្រមាថព្រះជាម្ចាស់ គឺវាប្រមាថព្រះនាម
របស់ព្រះអង្គប្រមាថព្រះពន្លា*របស់ព្រះអង្គនិង
ប្រមាថអស់អ្នក ដែលរស់នៅក្នុងស្ថានបរម
សុខ*។ ៧វាបានទទួលសិទ្ធិធ្វើសឹកសង្គ្រាម
ជាមួយប្រជាជនដ៏វិសុទ្ធ* ព្រមទាំងមានជ័យ
ជម្នះលើពួកគេទៀតផង[ក]។ វាបានទទួល
អំណាចត្រួតត្រាលើកុលសម្ព័ន្ធ*ទាំងអស់ប្រជា
រាស្ត្រទាំងអស់ ភាសាទាំងអស់និងជាតិសាសន៍
ទាំងអស់ ៨ហើយមនុស្សម្នានៅលើផែនដីនឹងនាំ
គ្នាក្រាបថ្វាយបង្គំវា។ អ្នកទាំងនោះគ្មានឈ្មោះ
កត់ទុកក្នុងបញ្ជី ជីវិតរបស់កូនចៀមដែលគេ
បានសម្លាប់ ជាបញ្ជីដែលមានតាំងពីដើម
កំណើតពិភពលោកនោះឡើយ។

៩ចូរផ្ទៀងត្រចៀកស្ដាប់ឲ្យមែនទែន!។១០
បើអ្នកណាត្រូវជាប់ជាឈ្លើយ អ្នកនោះមុខតែ
ជាប់ជាឈ្លើយអ្នកណាត្រូវស្លាប់នឹងមុខដាវ អ្នក
នោះមុខតែស្លាប់នឹងមុខដាវមិនខាន។ ដូច្នេះ
ប្រជាជនដ៏វិសុទ្ធ*ត្រូវមានចិត្តព្យាយាម និង
មានជំនឿ។

## សត្វតិរច្ឆានដែលចេញពីដី

១១បន្ទាប់មក ខ្ញុំឃើញសត្វតិរច្ឆានមួយទៀត
ផុសចេញពីដី មានស្នែងពីរ ដូចស្នែងកូនចៀម
ហើយមានសំឡេងដូចនាគ។ ១២សត្វនោះបាន
យកអំណាចទាំងអស់របស់សត្វទីមួយ មកប្រើ
នៅចំពោះមុខសត្វទីមួយ ទាំងនាំផែនដី និង
មនុស្សដែលរស់នៅលើផែនដីឲ្យក្រាបថ្វាយបង្គំ
សត្វទីមួយដែលមានរបួសជិតស្លាប់ ហើយបាន
ជាសះស្បើយវិញនោះផង។ ១៣សត្វនោះបាន
សម្ដែងទីសម្គាល់ដ៏សម្បើមអស្ចារ្យ រហូតដល់
ទៅធ្វើឲ្យមានភ្លើងធ្លាក់ចុះពីលើមេឃ មកផែនដី
ឲ្យមនុស្សលោកឃើញ។ ១៤វាបាននាំមនុស្ស
ដែលរស់នៅលើផែនដីនេះឲ្យវង្វេង ដោយធ្វើទី
សម្គាល់ផ្សេងៗនៅមុខសត្វទីមួយ តាមអំណាច
ដែលវាបានទទួល។ វាប្រាប់មនុស្សរស់នៅលើ
ផែនដីឲ្យឆ្លាក់រូបសត្វ ដែលត្រូវរបួសនឹងមុខដាវ
ហើយបានរួចជីវិតនោះ។ ១៥វាបានទទួល
អំណាច ធ្វើឲ្យរូបចម្លាក់សត្វនោះមានដង្ហើម
ឡើង ដើម្បីនិយាយស្ដីបាននិងប្រហារជីវិតអស់
អ្នក ដែលពុំព្រមក្រាបថ្វាយបង្គំរូបចម្លាក់សត្វ
នោះ ១៦វាបានបង្ខំមនុស្សទាំងអស់ទាំងអ្នកតូច
ទាំងអ្នកធំ ទាំងអ្នកមាន ទាំងអ្នកក្រ ទាំងអ្នកជា
ទាំងអ្នកងារ ឲ្យទទួលសញ្ញាសម្គាល់មួយនៅ
លើដៃស្ដាំ ឬនៅលើថ្ងាស។ ១៧ប្រសិនបើគ្មាន
សញ្ញាសម្គាល់នេះ គ្មានឈ្មោះរបស់សត្វ ឬ
គ្មានលេខសម្គាល់ឈ្មោះរបស់សត្វនោះទេគ្មាន
នរណាម្នាក់មានសិទ្ធិទិញ ឬលក់អ្វីបានសោះ
ឡើយ។១៨ត្រង់ហ្នឹងហើយ ដែលត្រូវមានប្រាជ្ញា
វិះគិត!។ អ្នកណាឆ្លាត ចូរយកលេខសម្គាល់
របស់សត្វនោះទៅគិតមើលទៅ ដ្បិតលេខនេះ
ជាលេខរបស់មនុស្ស គឺប្រាំមួយរយហុកសិប
ប្រាំមួយ។

## កូនចៀម និង
## អស់អ្នកដែលព្រះអង្គបានលោះ

១ខ្ញុំមើលទៅ ឃើញកូនចៀមឈរនៅលើភ្នំ
១៤ស៊ីយ៉ូន ហើយមានមនុស្សមួយសែនបួនម៉ឺន
បួនពាន់នាក់ នៅជាមួយព្រះអង្គ អ្នកទាំងនេះ
មានព្រះនាមកូនចៀម និងព្រះនាមព្រះបិតា
របស់ព្រះអង្គចារនៅលើថ្ងាស។ ២ខ្ញុំឮសំឡេង
មួយបន្លឺពីលើមេឃមក ស្នូរសន្ធឹកដូចមហា
សាគរ ឬដូចផ្គរលាន់យ៉ាងខ្លាំង។ សំឡេងដែល
ខ្ញុំឮមានសំនៀង ដូចពួកអ្នកលេងពិណកំពុង
ប្រគំដូរ្យតន្ត្រី។៣អ្នកទាំងនេះច្រៀងចម្រៀងថ្មី
នៅមុខបល្ល័ង្ក នៅមុខសត្វមានជីវិតទាំងបួននិង
នៅមុខពួកព្រឹទ្ធាចារ្យ។គ្មាននរណាម្នាក់ អាច
រៀនចម្រៀងនោះចេះឡើយ លើកលែងតែ
មនុស្សមួយសែនបួនម៉ឺនបួនពាន់នាក់ ដែលព្រះ
ជាម្ចាស់បានលោះពីផែនដីមក។ ៤អ្នកទាំងនេះ
សុទ្ធតែជាមនុស្ស ដែលពុំបានធ្វើឲ្យខ្លួនសៅ
ហ្មងនឹងស្ត្រីៗ[ខ]ឡើយ គឺគេនៅព្រហ្មចារីទាំង
អស់គ្នា។ កូនចៀមទៅទីណាគេក៏នាំគ្នាទៅទី
នោះ តាមព្រះអង្គដែរ។ ព្រះអង្គបានលោះគេ
ចេញពីចំណោមមនុស្សលោក មកទុកជាផល
ដំបូងថ្វាយព្រះជាម្ចាស់ និង ថ្វាយកូនចៀម
៥ហើយអ្នកទាំងនោះ ក៏មិនដែលពោលពាក្យ
កុហកដែរ គឺគេឥតមានសៅហ្មងត្រង់ណា
សោះឡើយ។

## ប្រកាសអំពីការវិនិច្ឆ័យទោស

៦ខ្ញុំឃើញទេវទូត*មួយរូបទៀត ហោះ
កណ្ដាលអាកាសវេហាស៍ទេវទូតនោះនាំដំណឹង
ល្អ*មួយ ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច
មកប្រាប់មនុស្សគ្រប់ជាតិសាសន៍ គ្រប់កុលស
ម្ព័ន្ធ គ្រប់ភាសា និងគ្រប់ប្រជាជនដែលរស់នៅ
លើផែនដី។ ៧ទេវទូតបន្លឺសំឡេងយ៉ាងខ្លាំងៗ
ថា៖ «ចូរនាំគ្នាគោរពកោតខ្លាចព្រះជាម្ចាស់
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គដ្បិត
ដល់ពេលព្រះអង្គវិនិច្ឆ័យទោសហើយ! ចូរនាំ
គ្នាក្រាបថ្វាយបង្គំព្រះអង្គ ដែលបានបង្កើតផ្ទៃ
មេឃផែនដី សមុទ្រ ព្រមទាំងប្រភពទឹកទាំង
ឡាយ!»។

៨មានទេវទូតមួយរូបទៀត មកតាមក្រោយ
ពោលថា៖ «រលំហើយ! រលំហើយ! ក្រុងបាប៊ី
ឡូនមហានគរ ដែលបាននាំជាតិសាសន៍ទាំង
ប៉ុន្មានឲ្យស្រវឹងនឹងកាមគុណ ដ៏ថោកទាបបំផុត
[គ]របស់វា!»។

៩មានទេវទូតមួយរូបទៀត ជាទេវទូតទីបី
មកតាមក្រោយ ពោលឡើងយ៉ាងខ្លាំងថា៖ «
អ្នកណាក្រាបថ្វាយបង្គំសត្វតិរច្ឆាននោះ និង
ក្រាបថ្វាយបង្គំរូបចម្លាក់របស់វា ព្រមទាំងទទួល
សញ្ញាសម្គាល់នៅលើថ្ងាស ឬនៅលើដៃ ១០អ្នក
នោះនឹងត្រូវទទួលទណ្ឌកម្ម ពីព្រះជាម្ចាស់ព្រះ
អង្គនឹងវិនិច្ឆ័យទោសគេ ឥតត្រាប្រណីឡើយ[ឃ]
ហើយគេនឹងត្រូវរងទុក្ខទោសនៅក្នុងភ្លើង និង
ក្នុងស្ពាន់ធ័រ នៅចំពោះមុខពួកទេវទូតដ៏វិសុទ្ធ*
និងនៅចំពោះព្រះភ័ក្ត្ររបស់កូនចៀម។១១ផ្សែង
ភ្លើងដែលធ្វើឲ្យគេរងទុក្ខទោស ហុយអស់កល្ប
ជាអង្វែងតរៀងទៅ។ អស់អ្នកដែលបានក្រាប
ថ្វាយបង្គំសត្វតិរច្ឆាន និងក្រាបថ្វាយបង្គំរូប
ចម្លាក់របស់វា ហើយបានទទួលសញ្ញាសម្គាល់

ឈ្មោះរបស់វាមុខជា ត្រូវវេទនាទាំងថ្ងៃទាំងយប់
ឥតស្រាកស្រាន្តឡើយ។

១២ ដូច្នេះ ប្រជាជនដ៏វិសុទ្ធ*គឺអស់អ្នកដែល
ប្រតិបត្តិតាមវិន័យ*របស់ព្រះជាម្ចាស់ និងកាន់
តាមជំនឿរបស់ព្រះយេស៊ូ ត្រូវមានចិត្តព្យាយា
ម។

១៣ ខ្ញុំឮសំឡេងមួយ បន្លឺពីលើមេឃមកថា៖
«ចូរសរសេរដូចតទៅ៖ អស់អ្នកដែលស្លាប់រួម
ជាមួយព្រះអម្ចាស់ ពិតជាមានសុភមង្គល*ចាប់
តាំងពីពេលនេះទៅហើយ! ព្រះវិញ្ញាណមាន
ព្រះបន្ទូលថាពិតមែន ហើយអ្នកទាំងនោះនឹង
បានឈប់សម្រាកលែងនឿយហត់ទៀត ដ្បិត
កិច្ចការដែលគេបានប្រព្រឹត្តទាំងប៉ុន្មាន នឹង
អន្ទោលតាមគេជាប់ជានិច្ច»។

## ការច្រូតកាត់និង ការបេះផ្លែទំពាំងបាយជូរ

១៤ ខ្ញុំមើលទៅឃើញពពក*សមួយដុំ ហើយ
មានម្នាក់ដូចបុត្រមនុស្ស* អង្គុយលើពពក
នោះ។ លោកពាក់មកុដមាសនៅលើក្បាល
ព្រមទាំងកាន់កណ្ដៀវមួយយ៉ាងមុតនៅដៃផង។
១៥ មានទេវទូតមួយរូបទៀតចេញពីព្រះវិហារ
មក ហើយស្រែកឡើងខ្លាំងៗ ទៅកាន់លោក
ដែលអង្គុយលើពពកថា៖ «សូមយកកណ្ដៀវ
របស់លោកមកច្រូតទៅ! ដល់ពេលច្រូតហើយ
ដ្បិតផែនដីទុំល្មមច្រូត[ង]ហើយ»។ ១៦ ពេលនោះ
លោកដែលអង្គុយនៅលើពពក បោះកណ្ដៀវ
មកផែនដី ផែនដីក៏ច្រូតស្រេចរួចរាល់។

១៧ មានទេវទូតមួយរូបទៀត ចេញពីព្រះ
វិហារនៅស្ថានបរមសុខ*មក លោកក៏មាន
កាំបិត[ច]មួយដ៏មុតដែរ។ ១៨ ទេវទូតមួយរូបទៀត
ដែលមានអំណាចលើភ្លើង បានចេញពីអាសនៈ
មកពោលខ្លាំងៗ ទៅកាន់ទេវទូតដែលកាន់
កាំបិតដ៏មុតថា៖ «សូមយកកាំបិតដ៏មុតរបស់
លោក មកកាត់ចង្កោមទំពាំងបាយជូរនៅលើ
ផែនដីទៅ ដ្បិតផ្លែវាទុំអស់ហើយ!»។ ១៩ ទេវ
ទូតនោះបោះកាំបិតរបស់លោក មកលើផែនដី
ផ្លែទំពាំងបាយជូរនៅលើផែនដីក៏កាត់រួចរាល់ជា
ស្រេច ហើយលោកបោះផ្លែទំពាំងបាយជូរទៅ
ក្នុងធុងបញ្ជាន់ផ្លែ ជាធុងនៃព្រះពិរោធដ៏ខ្លាំង
របស់ព្រះជាម្ចាស់។ ២០ បន្ទាប់មក គេយកធុង
ចេញទៅក្រៅទីក្រុង ដើម្បីបញ្ជាន់ផ្លែពេលនោះ
មានឈាមហូរចេញពីធុងមក មានកម្ពស់ត្រឹម
មាត់សេះ ចម្ងាយប្រមាណមួយពាន់ប្រាំមួយរយ
ស្ដាដ[ឆ]។

## ទេវទូតប្រាំពីររូបនិង គ្រោះកាចចុងក្រោយ

១ បន្ទាប់មក ខ្ញុំឃើញទីសម្គាល់មួយទៀត
១៥នៅលើមេឃ ជាទីសម្គាល់យ៉ាងធំ គួរស្ញែង
ខ្លាច គឺមានទេវទូត*ប្រាំពីររូបកាន់គ្រោះកាច
ប្រាំពីរ ដែលជាគ្រោះកាចចុងក្រោយបង្អស់
ដ្បិតគ្រោះកាចទាំងនេះនឹងធ្វើឲ្យព្រះជាម្ចាស់
ឈប់ព្រះពិរោធ*។
២ បន្ទាប់មកទៀត ខ្ញុំឃើញដូចជាមានស
មុទ្រមួយ ភ្លឺដូចកែវលាយជាមួយនឹងភ្លើង
ហើយអស់អ្នកដែលបានឈ្នះសត្វតិរច្ឆាន និង

ឈ្មោះរូបចម្លាក់របស់វា ព្រមទាំងឈ្មោះលេខឈ្មោះរបស់វាឈរ នៅលើសមុទ្រកែវនោះ។ ពួកគេកាន់ពិណរបស់ព្រះជាម្ចាស់ ៣ហើយនាំគ្នាច្រៀងចម្រៀងរបស់លោកម៉ូសេ ជាអ្នកបម្រើរបស់ព្រះជាម្ចាស់ និងចម្រៀងរបស់កូនចៀមថា៖

*«ឱព្រះជាអម្ចាស់ដ៏មានព្រះចេស្ដាលើអ្វីៗទាំងអស់អើយ ស្នាព្រះហស្ដរបស់ព្រះអង្គប្រសើរឧត្ដម គួរឲ្យកោតស្ញប់ស្ញែងពន់ពេកណាស់! ឱព្រះមហាក្សត្រនៃប្រជាជាតិទាំងឡាយអើយ មាគ៌ារបស់ព្រះអង្គសុទ្ធតែសុចរិត និងត្រឹមត្រូវទាំងអស់! ៤បពិត្រព្រះអម្ចាស់! តើមាននរណាមិនគោរពកោតខ្លាចព្រះនាមព្រះអង្គ! តើនរណាមិនលើកតម្កើងសិរីរុងរឿងនៃព្រះនាមព្រះអង្គ! ដ្បិតមានតែព្រះអង្គប៉ុណ្ណោះជាព្រះដ៏វិសុទ្ធ។មនុស្សគ្រប់ជាតិសាសន៍នឹងនាំគ្នាមកក្រាបថ្វាយបង្គំព្រះអង្គ ដ្បិតគេបានឃើញច្បាស់ថា ព្រះអង្គវិនិច្ឆ័យដោយយុត្តិធម៌»។*

៥ក្រោយមកទៀត ខ្ញុំមើលទៅឃើញព្រះវិហារនៅស្ថានបរមសុខ ដែលមានព្រះពន្លានៃសក្ខីភាព[ជ]បើកទ្វារចំហ។ ៦ទេវទូតទាំងប្រាំពីររូបដែលកាន់គ្រោះកាចទាំងប្រាំពីរ ក៏ចេញពីព្រះវិហារមក មានសម្លៀកបំពាក់ធ្វើពីក្រណាត់ទេសឯកសុទ្ធដ៏ភ្លឺផ្លេក ហើយមានខ្សែក្រវាត់មាសនៅដើមទ្រូងផង។ ៧សត្វមានជីវិតមួយក្នុងចំណោមសត្វមានជីវិតទាំងបួន បានប្រគល់ពែងមាសប្រាំពីរ ជូនទេវទូតទាំងប្រាំពីររូប។ ពែងទាំងនោះពេញទៅដោយព្រះពិរោធ របស់ព្រះជាម្ចាស់ ដែលគង់នៅអស់កល្បជាអង្វែងតរៀងទៅ។ ៨ព្រះវិហារក៏ពោរពេញទៅដោយផ្សែង ដែលចេញពីសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងពីឫទ្ធានុភាពរបស់ព្រះអង្គ ហើយគ្មាននរណា អាចចូលទៅក្នុងព្រះវិហារបានឡើយ ទាល់តែ គ្រោះកាចទាំងប្រាំពីររបស់ទេវទូតទាំងប្រាំពីរបានចប់សព្វគ្រប់ជាមុនសិន។

## ពែងមាសទាំងប្រាំពីរ

១ខ្ញុំបានឮសំឡេងមួយ យ៉ាងខ្លាំងចេញពី
១៦ព្រះវិហារ បន្លឺទៅកាន់ទេវទូតទាំងប្រាំពីរថា ៖ «ចូរនាំគ្នាទៅ ហើយយកពែងទាំងប្រាំពីរ នៃព្រះពិរោធរបស់ព្រះជាម្ចាស់ចាក់លើផែនដីទៅ!»។

២ទេវទូតទីមួយចេញទៅយកពែងរបស់ខ្លួនចាក់លើផែនដី ស្រាប់តែអស់អ្នកដែលមានសញ្ញាសម្គាល់របស់សត្វតិរច្ឆាន ហើយដែលក្រាបថ្វាយបង្គំរូបចម្លាក់របស់វា កើតដំបៅរលួយឈឺចុកចាប់យ៉ាងខ្លាំង។

៣ទេវទូតទីពីរ យកពែងរបស់ខ្លួនចាក់លើសមុទ្រ ស្រាប់តែសមុទ្រក្លាយទៅជាឈាម ដូចឈាមហូរចេញពីសាកសព ហើយអ្វីៗទាំងប៉ុន្មានដែលមានជីវិតក្នុងសមុទ្រ ក៏ស្លាប់អស់ទៅ។

៤ទេវទូតទីបី យកពែងរបស់ខ្លួនចាក់លើទន្លេ និងប្រភពទឹកនានាស្រាប់តែទន្លេ និងប្រភពទឹកក្លាយទៅជាឈាមទាំងអស់។ ៥ខ្ញុំឮទេវតាម្ចាស់ទឹកពោលថា៖ «បពិត្រ ព្រះអង្គដ៏មានព្រះជន្មគង់នៅសព្វថ្ងៃ និងមានព្រះជន្ម

គង់នៅតាំងពីដើមរៀងមក ព្រះអង្គពិតជាវិសុទ្ធ
ហើយទ្រង់វិនិច្ឆ័យទោស ដោយយុត្តិធម៌មែន!
៦ ដ្បិតអ្នកទាំងនោះ បានបង្ហូរឈាមប្រជាជនដ៏
សុទ្ធ* និងបង្ហូរឈាមពួកព្យាការី*ព្រះអង្គឲ្យ
ឈាមគេផឹកដូច្នេះសមមុខពួកគេហើយ»។៧ខ្ញុំ
ឮសំឡេងមួយចេញពីអាសនៈមកថា៖«ប្រាកដ
មែន! បពិត្រព្រះជាអម្ចាស់ជាព្រះដ៏មានព្រះ
ចេស្ដាលើអ្វីៗទាំងអស់ ព្រះអង្គវិនិច្ឆ័យទោស
យ៉ាងត្រឹមត្រូវតាមយុត្តិធម៌ពិតមែនហើយ!»។

៨ទេវទូតទីបួន យកពែងរបស់ខ្លួនចាក់ទៅ
លើព្រះអាទិត្យ ស្រាប់តែព្រះអាទិត្យទទួល
អំណាច ធ្វើឲ្យមនុស្សក្ដៅក្រហល់ក្រហាយ។
៩ មនុស្សម្នាត្រូវរលាកដោយកម្ដៅថ្ងៃ យ៉ាងខ្លាំង
គេនាំគ្នាជេរប្រមាថព្រះនាមព្រះជាម្ចាស់ដែល
មានអំណាចលើគ្រោះកាចទាំងនេះ តែគេពុំ
បានកែប្រែចិត្តគំនិត ហើយពុំព្រមលើកតម្កើង
សិរីរុងរឿងរបស់ព្រះអង្គឡើយ។

១០ទេវទូតទីប្រាំ យកពែងរបស់ខ្លួនចាក់ទៅ
លើបល្ល័ង្ករបស់សត្វតិរច្ឆាន ស្រាប់តែអាណា
ចក្ររបស់វាប្រែទៅជាងងឹតសូន្យ មនុស្សម្នានាំ
គ្នាខាំអណ្ដាតរបស់ខ្លួន ព្រោះវេទនាខ្លាំងពេក។
១១គេនាំគ្នាជេរប្រមាថព្រះជាម្ចាស់នៃស្ថានបរម
សុខ* ព្រោះតែឈឺចុកចាប់ និងកើតដំបៅពេញ
ខ្លួន។ ប៉ុណ្ណឹងហើយពួកគេនៅតែមិនកែប្រែចិត្ត
គំនិត លះបង់អំពើដែលខ្លួនធ្លាប់ប្រព្រឹត្តនោះ
ឡើយ។

១២ទេវទូតទីប្រាំមួយ យកពែងរបស់ខ្លួនចាក់
ទៅលើទន្លេធំ គឺទន្លេអឺប្រាតស្រាប់តែទឹករីង
អស់ ដើម្បីឲ្យទន្លេទៅជាផ្លូវមួយចាំទទួលស្ដេច
នានាមកពីបូព៌ាប្រទេស។ ១៣ខ្ញុំឃើញខ្មោច
បិសាចបី មួយចេញពីមាត់នាគ មួយចេញពី
មាត់សត្វតិរច្ឆាន និងមួយទៀតចេញពីមាត់ព្យា
ការីក្លែងក្លាយ។ ខ្មោចបិសាចទាំងនោះមានរូប
រាងដូចកង្កែប ១៤គឺជាវិញ្ញាណរបស់ពួកអារក្ស។
វាសម្ដែងទីសម្គាល់ផ្សេងៗនិងចេញទៅប្រមូល
ស្ដេចនៅលើផែនដីទាំងមូល ឲ្យធ្វើសឹកសង្គ្រាម
នៅថ្ងៃដ៏អស្ចារ្យ របស់ព្រះជាម្ចាស់ជាព្រះដ៏មាន
ព្រះចេស្ដាលើអ្វីៗទាំងអស់ ១៥(«មើល៍! យើង
នឹងមកដូចចោរចូលលួច។ អ្នកណាប្រុងស្មារតី
ហើយមានសម្លៀកបំពាក់បិទបាំងកាយ ឥតនៅ
អាក្រាតឲ្យគេឃើញកេរ្តិ៍ខ្មាស អ្នកនោះពិតជា
មានសុភមង្គល*ហើយ!»)។ ១៦ពួកខ្មោច
បិសាចនឹងប្រមូលស្ដេចទាំងនោះឲ្យមកជួបជុំ
គ្នានៅកន្លែងមួយដែលមានឈ្មោះជាភាសាហេ
ប្រឺថា«ហារម៉ាគេដូន»។

១៧ទេវទូតទីប្រាំពីរ យកពែងរបស់ខ្លួនចាក់
ទៅលើអាកាស ស្រាប់តែមានសំឡេងមួយបន្លឺ
ឡើងយ៉ាងខ្លាំង ចេញពីបល្ល័ង្កក្នុងព្រះវិហារ*ថា
៖ «រួចរាល់ស្រេចអស់ហើយ!»។ ១៨ពេលនោះ
មានផ្លេកបន្ទោរ មានឮសំឡេង មានផ្គរលាន់
និងមានរញ្ជួយផែនដីយ៉ាងខ្លាំង ចាប់តាំងពីមាន
មនុស្សរស់នៅលើផែនដីមក មិនដែលមាន
រញ្ជួយផែនដីខ្លាំងយ៉ាងនេះទេ។ ១៩មហានគរ
នោះបានបែកជាបី រីឯក្រុងនានារបស់ជាតិ
សាសន៍ទាំងប៉ុន្មានបានរលំអស់ ពេលនោះព្រះ
ជាម្ចាស់បាននឹកដល់មហានគរបាប៊ីឡូន ព្រះ
អង្គបានឲ្យក្រុងនេះផឹកស្រាពីពែងនៃព្រះពិរោធ
ដ៏ខ្លាំងបំផុតរបស់ព្រះអង្គ[ឈ]។ ២០កោះទាំង

ប៉ុន្មាននឹងរសាត់បាត់អស់ទៅហើយ ភ្នំទាំង
ឡាយក៏លែងមានទៀតដែរ។ ២១ពេលនោះ
មានព្រឹលធ្លាក់មកយ៉ាងខ្លាំងគ្រាប់ព្រឹលនីមួយៗ
មានទម្ងន់ប្រមាណជាងមួយចុង[៣] ធ្លាក់ចុះពីលើ
មេឃមកលើមនុស្សលោក។ គេក៏នាំគ្នាជេរ
ប្រមាថព្រះជាម្ចាស់ ព្រោះតែគ្រោះកាចដែល
កើតមានពីព្រឹលនោះ ជាគ្រោះកាចដ៏ខ្លាំងបំផុ
ត។

## ការវិនិច្ឆ័យទោសស្ត្រីពេស្យា

១បន្ទាប់មក ទេវទូត*មួយរូបក្នុងចំណោម
១៧ទេវទូតទាំងប្រាំពីរ ដែលកាន់ពែងទាំង
ប្រាំពីរចូលមកនិយាយនឹងខ្ញុំថា៖ «សុំអញ្ជើញ
មក ខ្ញុំនឹងបង្ហាញឲ្យលោកឃើញ ការវិនិច្ឆ័យ
ទោសស្ត្រីពេស្យាដ៏មានឈ្មោះល្បីដែលអង្គុយ
លើមហាសមុទ្រ។ ២ស្ដេចនៅផែនដីបាននាំគ្នា
ប្រាសចាកសីលធម៌ជាមួយស្ត្រីនោះ ហើយ
មនុស្សម្នានៅលើផែនដីក៏បាននាំគ្នាស្រវឹងនឹង
កាមគុណជាមួយនាងដែរ»។
៣ទេវទូតនោះ បានលើកវិញ្ញាណខ្ញុំឡើងនាំ
ទៅកាន់វាលរហោស្ថាន*។ នៅទីនោះ ខ្ញុំឃើញ
ស្ត្រីម្នាក់អង្គុយលើសត្វមួយសម្បុរក្រហមឆ្អិន
ឆ្អៅ ដែលមានសរសេរឈ្មោះផ្សេងៗពេញខ្លួនវា
ជាឈ្មោះប្រមាថព្រះជាម្ចាស់។ សត្វនោះមាន
ក្បាលប្រាំពីរ និងមានស្នែងដប់។ ៤ស្ត្រីនោះ
ស្លៀកពាក់ពណ៌ស្វាយ និងពណ៌ក្រហមឆ្អិនឆ្អៅ
ព្រមទាំងតុបតែងខ្លួនដោយពាក់មាសត្បូង និង
ពេជ្រទៀតផង។ នាងកាន់ពែងមាសមួយនៅដៃ
ពោរពេញទៅដោយអំពើគួរឲ្យស្អប់ខ្ពើម និង
កាមគុណដ៏ថោកទាបរបស់នាង។ ៥នៅលើ
ថ្ងាសនាង មានចារឈ្មោះមួយដ៏អាថ៌កំបាំងគឺ «
មហានគរបាប៊ីឡូនជាម្ដាយរបស់ពួកស្ត្រីពេស្យា
និងជាប្រភពនៃអំពើគួរឲ្យស្អប់ខ្ពើមនៅលើផែន
ដី»។ ៦ខ្ញុំឃើញស្ត្រីនោះស្រវឹងឈាមរបស់
ប្រជាជនដ៏វិសុទ្ធ* និងឈាមអស់អ្នកដែលជា
បន្ទាល់របស់ព្រះយេស៊ូ។ ពេលឃើញស្ត្រីនោះ
ខ្ញុំងឿងឆ្ងល់ខ្លាំងណាស់។ ៧ទេវទូតពោលមក
កាន់ខ្ញុំថា៖ «ហេតុអ្វីបានជាលោកងឿងឆ្ងល់
ដូច្នេះ? ខ្ញុំនឹងប្រាប់លោកឲ្យបានដឹងអត្ថន័យដ៏
អាថ៌កំបាំងអំពីស្ត្រីនោះ និងអំពីសត្វដែលនាង
ជិះ មានក្បាលប្រាំពីរ និងស្នែងដប់។ ៨សត្វ
ដែលលោកឃើញនោះនៅសម័យដើមមានជីវិត
តែឥឡូវនេះគ្មានទៀតទេ ហើយវានឹងឡើងពី
នរកអវិចីមក រួចវានឹងវិនាសបាត់ទៅវិញ។
ពេលឃើញសត្វនោះមនុស្សម្នារស់នៅលើផែន
ដី ដែលគ្មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិត តាំងពី
មុនកំណើតពិភពលោកមក នឹងងឿងឆ្ងល់យ៉ាង
ខ្លាំង ព្រោះនៅសម័យដើមវាមានជីវិត តែឥឡូវ
នេះគ្មានទៀតទេ ហើយវានឹងលេចមកសាជា
ថ្មី។ ៩ត្រង់នេះតោងយកប្រាជ្ញាដ៏ឈ្លាសវៃ មក
រិះគិតទើបយល់៖ ក្បាលប្រាំពីរសំដៅទៅលើភ្នំ
ទាំងប្រាំពីរដែលស្ត្រីនោះអង្គុយលើ ហើយក៏
សំដៅទៅលើស្ដេចទាំងប្រាំពីរអង្គដែរ។ ១០
ស្ដេចប្រាំអង្គបានធ្លាក់រាជ្យបាត់ទៅហើយ មួយ
អង្គទៀតកំពុងតែសោយរាជ្យ ហើយមួយអង្គ
ទៀតមិនទាន់មកដល់នៅឡើយទេ។ ពេល
ស្ដេចនោះមកដល់ ទ្រង់នឹងសោយរាជ្យតែមួយ
ភ្លែតប៉ុណ្ណោះ។ ១១រីឯសត្វតិរច្ឆាន ដែលមាន
ជីវិតកាលពីសម័យដើម តែឥឡូវគ្មានទេនោះ វា
នឹងមកធ្វើជាស្ដេចទីប្រាំបី។ វាក៏នៅក្នុង

ចំណោមស្ដេចទាំងប្រាំពីរនោះដែរហើយនឹងត្រូវ
វិនាសបាត់ទៅ។ ១២ស្នែងទាំងដប់ដែលលោក
បានឃើញ សំដៅទៅលើស្ដេចដប់អង្គដែលពុំ
ទាន់បានទទួលរាជ្យសម្បត្តិនៅឡើយ តែស្ដេច
ទាំងនោះនឹងទទួលអំណាចធ្វើជាស្ដេចបានមួយ
ម៉ោង រួមជាមួយសត្វតិរច្ឆាន។ ១៣ស្ដេចទាំង
នោះមានគោលបំណងតែមួយដូចគ្នា គឺប្រគល់
ឫទ្ធានុភាពនិងអំណាចខ្លួនទៅឲ្យសត្វតិរច្ឆាន។
១៤ស្ដេចទាំងដប់នឹងនាំគ្នាធ្វើសឹកជាមួយកូន
ចៀម តែកូនចៀមនឹងឈ្នះស្ដេចទាំងដប់ ដ្បិត
ព្រះអង្គជាព្រះអម្ចាស់លើអម្ចាស់នានា និងជា
ព្រះមហាក្សត្រលើមហាក្សត្រនានា។ រីឯអស់
អ្នកដែលនៅជាមួយកូនចៀម គឺអ្នកដែលព្រះជា
ម្ចាស់បានត្រាស់ហៅ និងបានជ្រើសរើស
ហើយដែលមានជំនឿដ៏ស្មោះ ក៏នឹងមានជ័យជំ
នះរួមជាមួយកូនចៀមដែរ»។

១៥ទេវទូតពោលមកកាន់ខ្ញុំទៀតថា៖ «
មហាសមុទ្រដែលលោកបានឃើញ គឺមហាស
មុទ្រដែលស្ត្រីពេស្យាអង្គុយលើនោះ សំដៅទៅ
លើប្រជារាស្ត្រមហាជនជាតិសាសន៍ និងភាសា
នានា។ ១៦រីឯស្នែងទាំងដប់ដែលលោកបាន
ឃើញ ព្រមទាំងសត្វតិរច្ឆាននឹងនាំគ្នាស្អប់ស្ត្រី
ពេស្យានោះហើយ ធ្វើឲ្យនាងនៅស្វាត់ជ្រងំទាំង
សម្រាតនាងឲ្យនៅខ្លួនទទេ គេនឹងស៊ីសាច់នាង
និងយកនាងទៅដុតក្នុងភ្លើងទៀតផង ១៧ដ្បិត
ព្រះជាម្ចាស់បានបណ្ដាលឲ្យពួកគេមានចិត្ត ធ្វើ
តាមផែនការរបស់ព្រះអង្គ គឺមូលមតិគ្នាប្រគល់
រាជ្យសម្បត្តិទៅឲ្យសត្វតិរច្ឆាន រហូតដល់ព្រះ
បន្ទូលរបស់ព្រះជាម្ចាស់ បានសម្រេចគ្រប់ប្រកា
រ។ ១៨រីឯស្ត្រីដែលលោកបានឃើញនោះ គឺជា
មហានគរដែលគ្រងរាជ្យលើស្ដេចនានានៅលើ
ផែនដី»។

## ក្រុងបាប៊ីឡូនរលំ

១ក្រោយមក ខ្ញុំឃើញទេវទូត*មួយរូបទៀត
១៨មានអំណាចដ៏ខ្លាំងពូកែ ចុះពីលើមេឃមក
ហើយសិរីរុងរឿងរបស់ទេវទូតនោះភ្លឺចាំង មក
លើផែនដី។ ២លោកបន្លឺសំឡេងឡើងយ៉ាង
ខ្លាំងៗថា៖ «រលំហើយ! មហានគរបាប៊ីឡូន
បានរលំហើយ!ដ។ ក្រុងនេះបានក្លាយទៅជា
លំនៅរបស់ពួកអារក្ស ជាជម្រករបស់ខ្មោចទាំង
អស់ ហើយក៏ជាជម្រករបស់សត្វស្លាបទាំង
ប៉ុន្មានដែលមិនបរិសុទ្ធគួរឲ្យខ្ពើម ៣ព្រោះក្រុង
នេះបាននាំសាសន៍ទាំងប៉ុន្មាន ឲ្យស្រវឹងនឹង
កាមគុណដ៏ថោកទាបបំផុតរបស់វា[ប]។ ពួកស្ដេច
នៅលើផែនដី នាំគ្នាប្រាសចាកសីលធម៌ជាមួយ
ក្រុងនេះ ហើយពួកឈ្មួញនៅលើផែនដីរកស៊ី
មានបានក៏ដោយសារតែឫទ្ធានុភាពនៃទ្រព្យ
សម្បត្តិដ៏ហូរហៀររបស់ក្រុងនេះដែរ»។
៤ខ្ញុំឮសំឡេងមួយទៀត ពីលើមេឃមកថា៖
«ប្រជារាស្ត្ររបស់យើងអើយ! ចូរនាំគ្នាចាក
ចេញពីក្រុងនេះទៅ[ឱ] ដើម្បីកុំឲ្យចូលរួមនឹងអំពើ
បាបរបស់គេ ហើយរងគ្រោះកាចជាមួយគេ
ឡើយ ៥ដ្បិតបាបរបស់ក្រុងនេះគរឡើងខ្ពស់
ដល់មេឃព្រះជាម្ចាស់នៅតែនឹកឃើញអំពើ
ទុច្ចរិតរបស់គេ។ ៦ចូរសងទៅក្រុងនេះឲ្យសម
នឹងអំពើដែលខ្លួនបានប្រព្រឹត្ត បើគេប្រព្រឹត្ត
យ៉ាងណា ត្រូវតបស្នងទៅគេវិញ មួយជាពីរ
ហើយចាក់បំពេញពែងដែលគេបានប្រុងប្រៀប

ស្រេចហើយនោះមួយជាពីរដែរ! ៧ក្រុងនេះ
បានតម្កើងខ្លួន និងរស់នៅយ៉ាងសម្បូរហូរហៀរ
ដល់កម្រិតណាត្រូវធ្វើឲ្យគេវេទនាខ្លោចផ្សា និង
កាន់ទុក្ខដល់កម្រិតនោះដែរ ដ្បិតគេបាន
និយាយក្នុងចិត្តថា៖ "អញអង្គុយសោយរាជ្យ
ក្នុងឋានៈជាមហាក្សត្រិយានី អញមិនមែនជា
ស្ត្រីមេម៉ាយទេ ហើយអញនឹងមិនកាន់ទុក្ខ
ឡើយ!"[ឈ]។ ៨ហេតុនេះគ្រោះកាចផ្សេងៗនឹង
កើតមានដល់ក្រុងនេះ ក្នុងថ្ងៃតែមួយគឺអ្នកក្រុង
នឹងត្រូវស្លាប់កាន់ទុក្ខស្រេកឃ្លាន ហើយនឹង
មានភ្លើងឆេះបំផ្លាញក្រុងថែមទៀតផង ដ្បិត
ព្រះជាអម្ចាស់ដែលវិនិច្ឆ័យទោសក្រុងនេះ ទ្រង់
ប្រកបដោយឥទ្ធិឫទ្ធី។ ៩ពេលស្តេចនានានៅ
លើផែនដីដែលបានប្រាសចាកសីលធម៌ជាមួយ
ក្រុងនេះ ព្រមទាំងឈ្លក់នឹងទ្រព្យសម្បត្តិដ៏ហូរ
ហៀររបស់វា ឃើញផ្សែងហុយឡើងពីក្រុង
ដែលកំពុងតែឆេះ មុខជាយំសោកសង្រេង
អាណិតក្រុងនេះមិនខាន។ ១០ស្តេចទាំងនោះ
ឈរពីចម្ងាយ ដោយតក់ស្លុតនឹងទុក្ខទោស
ដែលកើតមានដល់ក្រុងនេះ ហើយនាំគ្នាពោល
ថា "វេទនាហើយ! វេទនាហើយមហានគរ
អើយ! ក្រុងបាប៊ីឡូនដ៏ខ្លាំងពូកែអើយ! ក្នុងរ
យៈពេលតែមួយម៉ោង អ្នកត្រូវវិនាសអន្តរាយ
អស់"។ ១១ពេលនោះ ពួកឈ្មួញនៅលើផែនដី
ក៏នាំគ្នាយំសោក និងកាន់ទុក្ខព្រោះតែក្រុងនេះ
ដែរ ដ្បិតគ្មាននរណាទិញទំនិញរបស់ខ្លួនទៀត
ឡើយ ១២ទំនិញទាំងនោះគឺ មាស ប្រាក់ ត្បូង
ពេជ្រ ក្រណាត់ទេសឯក ក្រណាត់ពណ៌ស្វាយ
ក្រណាត់សូត្រ ក្រណាត់ពណ៌ក្រហម ឈើ
ក្រអូបគ្រប់មុខ គ្រឿងភ្លុក គ្រឿងផ្សេងៗដែល
ធ្វើពីឈើដ៏មានតម្លៃ ធ្វើពីលង្ហិន ធ្វើពីដែក និង
ធ្វើពីថ្មកែវ ១៣សំបកសម្បុរល្វែង[ណ]សំបកខ្លឹម
ចន្ទទឹកអប់ ជ័រល្វីងទេស គ្រឿងក្រអូបស្រា
ប្រេងម្សៅម៉ដ្ឋ ស្រូវ គោ ចៀម សេះ រទេះ
អ្នកងារ និងអ្នកជាប់ឈ្លើយ[ត]។ ១៤ពួកឈ្មួញ
ទាំងនោះពោលទៅកាន់ក្រុងបាប៊ីឡូនថា៖
"ភោគផលទាំងប៉ុន្មានដែលអ្នកប្រាថ្នាចង់បាន
នោះ រសាត់បាត់អស់ទៅហើយ វត្ថុដ៏មានតម្លៃ
និងមានលំអដ៏ប្រណីតទាំងប៉ុន្មាននោះ អ្នកបាត់
បង់ទាំងអស់គ្មាននរណារកបានទៀតឡើយ!"
។ ១៥ពួកឈ្មួញដែលរកស៊ីមានបានដោយលក់
ទំនិញនៅក្រុងនេះនាំគ្នាឈរពីចម្ងាយ ដោយ
តក់ស្លុតនឹងទុក្ខទោសដែលកើតមានដល់ក្រុង
ទាំងយំសោកនិងកាន់ទុក្ខទៀតផង។ ១៦គេ
ពោលថា "វេទនាហើយ! វេទនាហើយ មហា
នគរដែលមានសម្លៀកបំពាក់ធ្វើពីក្រណាត់
ទេសឯក ក្រណាត់ពណ៌ស្វាយ និងពណ៌
ក្រហមឆ្អិនឆ្អៅ ព្រមទាំងពាក់មាស ត្បូងនិង
ពេជ្រ តុបតែងខ្លួន! ១៧ភោគសម្បត្តិដ៏ច្រើននេះ
បានវិនាសហិនហោចអស់ តែក្នុងរយៈពេល
មួយម៉ោងប៉ុណ្ណោះ!"។ ពួកអ្នកបើកសំពៅពួក
អ្នកជិះសំពៅតាមនោះកម្មករសំពៅ និងអ្នករក
ស៊ីតាមជើងទឹកទាំងប៉ុន្មាន[ថ]នាំគ្នានៅពីចម្ងា
យ។ ១៨ពេលឃើញផ្សែងហុយឡើងពីក្រុង
ដែលកំពុងតែឆេះ គេនាំគ្នាស្រែកថា "តើមាន
ក្រុងណា អាចប្រៀបផ្ទឹមនឹងមហានគរនេះ
បាន!"។ ១៩គេបាចធូលីដីលើក្បាលរបស់ខ្លួន
ហើយនាំគ្នាយំសោក និងកាន់ទុក្ខទាំងពោលថា
៖ "វេទនាហើយ! វេទនាហើយ!មហានគរ
ដែលធ្វើឲ្យពួកម្ចាស់សំពៅនៅតាមសមុទ្រ រក

ស៊ីមានបានដោយសារតែភោគសម្បត្តិរបស់
ក្រុងនេះ។ ក្នុងពេលតែមួយម៉ោងក្រុងនេះទៅ
ជាស្ងាត់ជ្រងំ!"។

[២០]ស្ថានបរមសុខអើយ ចូរអរសប្បាយនឹង
ការវិនាសរបស់ក្រុងនេះទៅ! អ្នករាល់គ្នាដែល
ជាប្រជាជនដ៏វិសុទ្ធ* គ្រីស្ដទូត* និងព្យាការី*
ចូរអរសប្បាយដែរ ដ្បិតព្រះជាម្ចាស់បានរក
យុត្តិធម៌ឲ្យអ្នករាល់គ្នា ដោយដាក់ទោសក្រុង
នេះហើយ»។

[២១]ពេលនោះ ទេវទូត*មួយរូបដ៏មានឥទ្ធិ
ឫទ្ធិ បានលើកថ្មមួយដុំដូចត្បាល់កិន បោះទៅ
ក្នុងសមុទ្រទាំងពោលថា៖ «គេនឹងប្រានក្រុងបា
ប៊ីឡូនមហានគរ ទម្លាក់ទៅក្នុងសមុទ្រដូច្នោះ
ដែរ!។ គ្មាននរណារកក្រុងនោះឃើញទៀត
ឡើយ[ទ]។ [២២]គេនឹងលែងឮសំឡេងដូរ្យតន្ត្រី
របស់ពួកអ្នកលេងពិណ អ្នកភ្លេង អ្នកផ្លុំខ្លុយ
និងអ្នកផ្លុំត្រែ ក្នុងឯងទៀតហើយ។ រីឯពួកជាង
ទាំងឡាយដែលប្រកបរបរគ្រប់មុខ ក៏លែងមាន
ហើយសំឡេងត្បាល់កិន ក៏លែងឮទៀតដែរ។
[២៣]ក្នុងឯងលែងមានពន្លឺចង្កៀងទៀត សំឡេងគូ
ស្វាមីភរិយាថ្មោងថ្មីក៏លែងឮទៀតដែរ ដ្បិតពួក
ឈ្មួញដែលរកស៊ីក្នុងឯង សុទ្ធតែជាអ្នកធំជាង
គេ នៅលើផែនដីនេះ វិជ្ជាធ្មប់របស់ឯងបាននាំ
ជាតិសាសន៍ទាំងអស់ឲ្យវង្វេង [២៤]ហើយនៅក្នុង
ឯងឃើញមានឈាមរបស់ពួកព្យាការី ឈាម
របស់ប្រជាជនដ៏វិសុទ្ធ និងឈាមរបស់អស់អ្នក
ដែលត្រូវគេសម្លាប់ នៅលើផែនដីនេះ»។

## ចម្រៀងជោគជ័យ និង

## ទិវាមង្គលការរបស់កូនចៀម

[១]បន្ទាប់ពីហេតុការណ៍ទាំងនោះមក ខ្ញុំឮ
១៩ហាក់ដូចជា មានសំឡេងយ៉ាងខ្លាំងរបស់
មហាជនច្រើនកុះករនៅលើមេឃថា៖ «ហាលេ
លូយ៉ា![ធ] សូមលើកតម្កើងព្រះជាម្ចាស់នៃយើង
ព្រះអង្គសង្គ្រោះយើង ព្រះអង្គប្រកបដោយសិរី
រុងរឿងនិងឫទ្ធានុភាព [២]ដ្បិតទ្រង់វិនិច្ឆ័យទោស
យ៉ាងត្រឹមត្រូវតាមយុត្តិធម៌។ ព្រះអង្គបានវិនិច្ឆ័
យទោសស្ត្រីពេស្យាដ៏មានឈ្មោះល្បី ដែលបាន
ធ្វើឲ្យផែនដីទៅជាសៅហ្មង ដោយកាមគុណ
របស់នាង ព្រះអង្គបានដាក់ទោសស្ត្រីពេស្យា
នោះ ព្រោះនាងបានបង្ហូរ ឈាមពួកអ្នកបម្រើ
របស់ព្រះអង្គ»។ [៣]មហាជនទាំងនោះពោល
ម្ដងទៀតថា៖ «ហាលេលូយ៉ា! ផ្សែងនៃក្រុង
នោះ នឹងហុយឡើងអស់កល្បជាអង្វែងតរៀង
ទៅ»។

[៤]ពួកព្រឹទ្ធាចារ្យទាំងម្ភៃបួនរូប និងសត្វមាន
ជីវិតទាំងបួនក៏នាំគ្នាក្រាបចុះ ហើយថ្វាយបង្គំ
ព្រះជាម្ចាស់ដែលគង់នៅលើបល្ល័ង្ក ទាំងពោល
ថា៖ «អាម៉ែន! ហាលេលូយ៉ា!»។ [៥]មាន
សំឡេងចេញពីបល្ល័ង្កមកថា៖ «អ្នករាល់គ្នាជា
អ្នកបម្រើព្រះជាម្ចាស់ អ្នករាល់គ្នាជាអ្នកគោរព
កោតខ្លាច ព្រះអង្គទាំងតូចទាំងធំអើយចូរ
សរសើរតម្កើងព្រះជាម្ចាស់នៃយើង!»។ [៦]ពេល
នោះ ខ្ញុំឮហាក់ដូចជាមានសំឡេងបណ្ដាជនដ៏
ច្រើនកុះករ ដូចជាមានស្នូរសន្ធឹកមហាសាគរ
និងដូចជាមានស្នូរផ្គរលាន់យ៉ាងខ្លាំងថា៖ «ហា
លេលូយ៉ា! ដ្បិតព្រះជាអម្ចាស់ជាព្រះដ៏មានព្រះ
ចេស្ដាលើអ្វីៗទាំងអស់ ទ្រង់បានតាំងព្រះរាជ្យ

របស់ព្រះអង្គហើយ ៧យើងនាំគ្នាអរសប្បាយ
ឡើង ត្រូវមានអំណររីករាយឲ្យខ្លាំងហើយនាំគ្នា
លើកតម្កើងសិរីរុងរឿង ព្រះអង្គដ្បិតដល់ពេល
រៀបវិវាហៈមង្គលការកូនចៀម ហើយភរិយា[ន]
ថ្មោងថ្មីរបស់កូនចៀម ក៏បានរៀបចំខ្លួនរួចជា
ស្រេចហើយដែរ។ ៨ព្រះអង្គប្រទានឲ្យនាង
ស្លៀកពាក់រុងរឿងភ្លឺចិញ្ចែងចិញ្ចាចនិងបរិសុទ្ធ។
សម្លៀកបំពាក់ដ៏រុងរឿងនោះ គឺជាអំពើសុចរិត
ផ្សេងៗ ដែលប្រជាជនដ៏វិសុទ្ធបានប្រព្រឹត្ត»។

៩ទេវទូត*ពោលមកកាន់ខ្ញុំថា៖ «ចូរកត់ត្រា
ទុកអ្នកណា ដែលព្រះជាម្ចាស់បានត្រាស់ហៅ
ឲ្យមកចូលរួម ក្នុងពិធីជប់លៀងមង្គលការកូន
ចៀម អ្នកនោះពិតជាមានសុភមង្គល*ហើយ!»
បន្ទាប់មកទេវទូតប្រាប់ខ្ញុំថា៖ «សេចក្ដីទាំងនេះ
ពិតជាព្រះបន្ទូលរបស់ព្រះជាម្ចាស់មែន»។១០ខ្ញុំ
ក៏ក្រាបចុះនៅទៀបជើងទេវទូតនោះ បម្រុងនឹង
ថ្វាយបង្គំលោក ប៉ុន្តែលោកពោលមកខ្ញុំថា៖ «កុំ
ថ្វាយបង្គំខ្ញុំអី! ខ្ញុំជាអ្នករួមការងារជាមួយលោក
ទេតើ ហើយខ្ញុំក៏រួមការងារជាមួយបងប្អូនលោក
ដែលជឿលើ សក្ខីភាពរបស់ព្រះយេស៊ូដែរ។
ត្រូវថ្វាយបង្គំព្រះជាម្ចាស់វិញ! ដ្បិតសក្ខីភាព
របស់ព្រះយេស៊ូ គឺវិញ្ញាណដែលថ្លែងព្រះបន្ទូល
ក្នុងនាមព្រះជាម្ចាស់»[ប]។

## ជ័យជំនះរបស់ព្រះគ្រិស្តលើសត្វតិរច្ឆាននិងលើព្យាការីក្លែងក្លាយ

១១បន្ទាប់មក ខ្ញុំឃើញផ្ទៃមេឃបើកចំហ
ហើយឃើញសេះសមួយលេចមក។ ព្រះអង្គ
ដែលគង់នៅលើសេះនោះមានព្រះនាមថា«ព្រះ
ដ៏ស្មោះត្រង់ ព្រះដ៏ពិតប្រាកដ» ទ្រង់វិនិច្ឆ័យនិង
ច្បាំងប្រកបដោយយុត្តិធម៌។ ១២ព្រះអង្គមាន
ព្រះនេត្រដូចអណ្ដាតភ្លើង ហើយមានមកុដជា
ច្រើននៅលើព្រះសិរសាផង។ នៅលើព្រះកាយ
ព្រះអង្គមានសរសេរព្រះនាមមួយក្រៅពីព្រះអង្គ
គ្មាននរណាស្គាល់ព្រះនាមនោះឡើយ ១៣ព្រះ
អង្គមានសម្លៀកបំពាក់ទទឹកឈាមជោក។ ព្រះ
អង្គមានព្រះនាមថា «ព្រះបន្ទូលរបស់ព្រះជា
ម្ចាស់»។ ១៤កងទ័ពនៅស្ថានសួគ៌នាំគ្នាជិះសេះ
សមកតាមព្រះអង្គ ទាំងស្លៀកពាក់សំពត់ទេស
ឯកពណ៌ស និងបរិសុទ្ធ*។ ១៥មានដាវមួយ
យ៉ាងមុតចេញពីព្រះឱស្ឋរបស់ព្រះអង្គ មក
ប្រហារជាតិសាសន៍ទាំងឡាយ ព្រះអង្គនឹងកាន់
ដំបងដែកដឹកនាំគេ[ផ] ហើយព្រះអង្គជាន់ទំពាំង
បាយជូរនៅក្នុងធុង ឲ្យចេញជាស្រានៃព្រះ
ពិរោធដ៏ខ្លាំងក្លារបស់ព្រះជាម្ចាស់ ដ៏មានព្រះ
ចេស្ដាលើអ្វីៗទាំងអស់។ ១៦នៅលើព្រះភូសា
និងលើភ្លៅរបស់ព្រះអង្គ មានសរសេរព្រះនាម
ថា «ព្រះមហាក្សត្រលើមហាក្សត្រនានា និង
ព្រះអម្ចាស់លើអម្ចាស់នានា»។

១៧ខ្ញុំឃើញទេវទូត*មួយរូប ឈរនៅក្នុង
ព្រះអាទិត្យ។ ទេវទូតនោះបន្លឺសំឡេងខ្លាំងៗ
ទៅកាន់សត្វស្លាបទាំងអស់ ដែលហើរនៅ
កណ្ដាលអាកាសវេហាស៍ថា៖ «ចូរនាំគ្នាមក!
ចូរប្រមូលគ្នាមកចូលរួមក្នុងពិធីជប់លៀង ដ៏
មហោឡារិករបស់ព្រះជាម្ចាស់ ១៨ដើម្បីស៊ីសាច់
ពួកស្ដេចសាច់ពួកមេទ័ព សាច់ពួកអ្នកខ្លាំងពូកែ
សាច់សេះនិងសាច់ពួកអ្នកជិះសេះ ព្រមទាំង
សាច់មនុស្សទាំងអស់ គឺទាំងអ្នកជា ទាំងអ្នក

ងារ ទាំងអ្នកតូច ទាំងអ្នកធំ»។

១៩ខ្ញុំឃើញសត្វតិរច្ឆាន និងពួកស្ដេចនានា
នៅលើផែនដី ព្រមទាំងកងទ័ពរបស់គេប្រមូល
គ្នាមកច្បាំងនឹងព្រះអង្គ ដែលគង់នៅលើសេះ
និងកងទ័ពរបស់ព្រះអង្គ។ ២០សត្វតិរច្ឆានបាន
ជាប់ជាឈ្លើយសឹក ហើយព្យាការីក្លែងក្លាយ
ដែលបានសម្ដែងទីសម្គាល់អស្ចារ្យ នៅមុខសត្វ
នោះ ក៏បានជាប់ជាឈ្លើយដែរ គឺព្យាការីក្លែង
ក្លាយហ្នឹង ហើយដែលបាននាំអស់អ្នកមាន
សញ្ញាសម្គាល់របស់សត្វតិរច្ឆាន និងអ្នកក្រាប
ថ្វាយបង្គំរូបចម្លាក់របស់សត្វនោះឲ្យវង្វេង។ គេ
បានបោះពួកសត្វតិរច្ឆាន និងព្យាការីក្លែងក្លាយ
ទាំងរស់ទៅក្នុងបឹងភ្លើង ដែលមានស្ពាន់ធ័រ
កំពុងឆេះ។ ២១រីឯអ្នកឯទៀតៗក៏បានស្លាប់
ដោយដាវ ចេញមកពីព្រះឱស្ឋរបស់ព្រះអង្គ
ដែលគង់នៅលើសេះ ហើយសត្វស្លាបទាំង
ប៉ុន្មានក៏បានស៊ីសាច់ពួកគេឆ្អែតរៀងៗខ្លួន។

## រាជ្យមួយពាន់ឆ្នាំ

១បន្ទាប់មក ខ្ញុំឃើញទេវទូត*មួយរូបចុះពី
២០លើមេឃ ទាំងកាន់កូនសោស្ថាននរកអវិចី
និងច្រវាក់មួយយ៉ាងធំនៅដៃផង។ ២ទេវទូត
នោះបានចាប់នាគមកចងទុក ក្នុងរយៈពេល
មួយពាន់ឆ្នាំ។ នាគនោះជាពស់ពីបុរាណ[ក]ជា
មារ* និងជាសាតាំង។ ៣ទេវទូតបានបោះវាទៅ
ស្ថាននរកអវិចី ហើយចាក់សោបិទត្រាលើទ្វារ
រហូតដល់គម្រប់មួយពាន់ឆ្នាំ ដើម្បីកុំឲ្យវាល្បួង
ជាតិសាសន៍នានាឲ្យវង្វេងទៀត។ លុះផុត
កំណត់នេះទៅត្រូវតែដោះលែងវាមួយរយៈ
ពេលខ្លី។

៤ខ្ញុំឃើញបល្ល័ង្កជាច្រើន ហើយអស់អ្នក
ដែលអង្គុយនៅលើបល្ល័ង្កទាំងនោះ បានទទួល
អំណាចនឹងវិនិច្ឆ័យទោស។ ខ្ញុំក៏ឃើញវិញ្ញាណ
ក្ខន្ធរបស់អស់អ្នក ដែលស្លាប់ដោយគេកាត់ក
ព្រោះតែបានផ្ដល់សក្ខីភាពអំពីព្រះយេស៊ូ និង
អំពីព្រះបន្ទូលរបស់ព្រះអង្គ។ ខ្ញុំក៏ឃើញ
វិញ្ញាណក្ខន្ធរបស់អស់អ្នក ដែលមិនបានក្រាប
ថ្វាយបង្គំសត្វតិរច្ឆាន ឬថ្វាយបង្គំរូបចម្លាក់របស់
វា ហើយមិនបានទទួលសញ្ញាសម្គាល់លើថ្ងាស
និងនៅលើដៃដែរ[ខ]។ អ្នកទាំងនោះមានជីវិតរស់
ឡើងវិញ សោយរាជ្យជាមួយព្រះគ្រិស្ដក្នុងរយៈ
ពេលមួយពាន់ឆ្នាំ។ ៥រីឯមនុស្សឯទៀតៗដែល
បានស្លាប់ទៅហើយនោះ ពុំបានរស់ឡើងវិញទេ
គឺរហូតដល់គម្រប់មួយពាន់ឆ្នាំ ទើបរស់ឡើងវិ
ញ។ នេះជាការរស់ឡើងវិញលើកទីមួយ ៦ អស់
អ្នកដែលបានរស់ឡើងវិញ នៅលើកទីមួយ ពិត
ជាមានសុភមង្គល*ហើយនឹងបានវិសុទ្ធ*ទៀត
ផង!។ សេចក្ដីស្លាប់ទីពីរគ្មានអំណាចលើអ្នក
ទាំងនោះឡើយ ផ្ទុយទៅវិញ គេនឹងទៅជាបូជា
ចារ្យ*របស់ព្រះជាម្ចាស់ និងរបស់ព្រះគ្រិស្ដ
ហើយសោយរាជ្យជាមួយព្រះអង្គ ក្នុងរយៈ
ពេលមួយពាន់ឆ្នាំ។

## បរាជ័យរបស់មារសាតាំង

៧លុះរយៈពេលមួយពាន់ឆ្នាំនោះ កន្លងផុត
ទៅ មារសាតាំងនឹងរួចពីគុក ៨ហើយវាចេញទៅ
បញ្ឆោតជាតិសាសន៍នានា នៅទិសទាំងបួន ឲ្យ
វង្វេងគឺវានាំទាំងសាសន៍គុក ទាំងសាសន៍ម៉ា
កុក[គ] ឲ្យវង្វេងដែរ ដើម្បីប្រមូលគេមកធ្វើសឹកស

ង្គ្រាម។ ពួកគេមានចំនួនច្រើនដូចគ្រាប់ខ្សាច់
នៅឆ្នេរសមុទ្រ។ ៩ពួកគេបានឡើងទៅច្បាំង
ពាសពេញលើផែនដីទាំងមូល ហើយឡោមព័ទ្ធ
ទីបោះជំរំរបស់ប្រជារាស្ត្រព្រះជាម្ចាស់ ព្រម
ទាំងឡោមព័ទ្ធក្រុងដ៏ជាទីស្រឡាញ់ របស់ព្រះ
អង្គថែមទៀតផង។ ក៏ប៉ុន្តែមានភ្លើងធ្លាក់ពីលើ
មេឃមកលេបពួកគេអស់ទៅ។ ១០រីឯមារដែល
បាននាំជាតិសាសន៍ទាំងនោះឲ្យវង្វេង ក៏ត្រូវគេ
បោះទៅក្នុងបឹងភ្លើង និងស្ពាន់ធ័រដែលមានសត្វ
តិរច្ឆាន និងព្យាការីក្លែងក្លាយនៅក្នុងនោះស្រា
ប់។ គេនឹងរងទុក្ខវេទនាទាំងថ្ងៃទាំងយប់អស់
កល្បជាអង្វែងតរៀងទៅ។

## ការវិនិច្ឆ័យទោសចុងក្រោយបង្អស់

១១បន្ទាប់មក ខ្ញុំឃើញបល្ល័ង្កមួយធំពណ៌ស
ព្រមទាំងឃើញព្រះអង្គ ដែលគង់នៅលើបល្ល័ង្ក
នោះផងដែរ។ ផែនដីនិងផ្ទៃមេឃបានរត់ចេញ
បាត់ពីព្រះភ័ក្ត្រព្រះអង្គទៅ ឥតមានសល់អ្វីឡើ
យ។ ១២ខ្ញុំក៏ឃើញមនុស្សស្លាប់ ទាំងអ្នកធំទាំង
អ្នកតូច ឈរនៅមុខបល្ល័ង្កហើយមានក្រាំងជា
ច្រើនបើកជាស្រេច មានក្រាំងមួយទៀតបើក
ដែរ គឺក្រាំងនៃបញ្ជីជីវិត។ ព្រះអង្គដែលគង់នៅ
លើបល្ល័ង្ក ទ្រង់វិនិច្ឆ័យទោសមនុស្សស្លាប់ទាំង
អស់ តាមអំពើដែលគេបានប្រព្រឹត្ត ដូចមានកត់
ត្រាទុកក្នុងក្រាំងទាំងនោះស្រាប់។ ១៣សមុទ្រ
បានប្រគល់មនុស្សស្លាប់ ដែលនៅក្នុងទឹកមក
វិញ សេចក្ដីស្លាប់និងស្ថានមច្ចុរាជក៏បានប្រគល់
មនុស្សស្លាប់ ដែលនៅទីនោះមកវិញដែរ ហើយ
ព្រះអង្គនឹងវិនិច្ឆ័យទោសម្នាក់ៗ តាមអំពើដែល
ខ្លួនបានប្រព្រឹត្ត។ ១៤សេចក្ដីស្លាប់និងស្ថានមច្ចុ
រាជត្រូវគេបោះទៅក្នុងបឹងភ្លើង។ បឹងភ្លើងនេះ
ហើយជាសេចក្ដីស្លាប់ទីពីរ។ ១៥អស់អ្នកដែល
គ្មានឈ្មោះក្នុងបញ្ជីជីវិត ក៏នឹងត្រូវបោះទៅក្នុង
បឹងភ្លើងដែរ។

## ផ្ទៃមេឃថ្មីនិងផែនដីថ្មី

១ពេលនោះ ខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដី
២១ថ្មី ដ្បិតផ្ទៃមេឃពីមុននិងផែនដីពីមុននោះ
បាត់អស់ទៅហើយ ហើយក៏គ្មានសមុទ្រទៀត
ដែរ។ ២បន្ទាប់មក ខ្ញុំឃើញក្រុងដ៏វិសុទ្ធ*ជា
ក្រុងយេរូសាឡឹមថ្មីចុះពីស្ថានបរមសុខ* គឺចុះ
មកពីព្រះជាម្ចាស់ ទាំងតែងខ្លួនដូចភរិយាថ្មោង
ថ្មីតុបតែងខ្លួនទទួលស្វាមី។ ៣ខ្ញុំឮសំឡេងបន្លឺ
យ៉ាងខ្លាំងៗចេញពីបល្ល័ង្កមកថា៖«មើលហ្ន៎ព្រះ
ពន្លា[យ]របស់ព្រះជាម្ចាស់ ស្ថិតនៅជាមួយមនុស្ស
លោកហើយ! ព្រះអង្គនឹងស្ថិតនៅក្នុងចំណោម
ពួកគេ ពួកគេនឹងទៅជាប្រជារាស្ត្ររបស់ព្រះអង្គ
ហើយព្រះជាម្ចាស់ផ្ទាល់នឹងគង់ជាមួយពួកគេ។
៤ព្រះអង្គនឹងជូតទឹកភ្នែកចេញអស់ពីភ្នែករបស់
គេ សេចក្ដីស្លាប់លែងមានទៀតហើយ ការកាន់
ទុក្ខ ការសោកសង្រេង និងទុក្ខលំបាក ក៏លែង
មានទៀតដែរ ដ្បិតអ្វីៗដែលកើតមានកាលពី
មុននោះ បាត់អស់ទៅហើយ»។
៥ព្រះអង្គដែលគង់នៅលើបល្ល័ង្ក ទ្រង់មាន
ព្រះបន្ទូលថា៖ «មើល៍យើងបានធ្វើអ្វីៗទាំង
អស់សុទ្ធតែថ្មី»។ រួចព្រះអង្គមានព្រះបន្ទូល
ទៀតថា៖ «ចូរកត់ត្រាទុក ដ្បិតសេចក្ដីទាំងនេះ
សុទ្ធតែជាពាក្យពិតគួរឲ្យជឿ»។ ៦ព្រះអង្គមាន
ព្រះបន្ទូលមកខ្ញុំថា៖ «រួចស្រេចអស់ហើយ!
យើងជាអាល់ផានិងជាអូមេកា គឺជាដើមដំបូង

និងជាចុងបំផុត។ អ្នកណាស្រេកយើងនឹងឲ្យ
ទឹកដែលហូរចេញពីប្រភពជីវិត ទៅអ្នកនោះ
ដោយគេមិនបាច់បង់ថ្លៃឡើយ។ [៧]អ្នកដែល
មានជ័យជម្នះមុខជាបានទទួលមត៌កបែបនេះឯ
ង។ យើងនឹងធ្វើជាព្រះរបស់គេ ហើយគេធ្វើជា
បុត្រធីតារបស់យើង។ ពួកកំសាក ពួកមិនជឿ
ពួកប្រព្រឹត្តអំពើគួរស្អប់ខ្ពើម ពួកសម្លាប់គេ ពួក
ប្រាសចាកសីលធម៌ ពួកគ្រូធ្មប់ ពួកថ្វាយបង្គំ
ព្រះក្លែងក្លាយ និងពួកកុហកទាំងប៉ុន្មាន នឹង
ទទួលទោសនៅក្នុងបឹងភ្លើង និងស្ពាន់ធ័រដែល
កំពុងតែឆេះ»។ នេះហើយជាសេចក្ដីស្លាប់ទីពី
រ។

## ក្រុងយេរូសាឡឹមថ្មី

[៩]បន្ទាប់មក ទេវទូត*មួយរូបក្នុងចំណោម
ទេវទូតទាំងប្រាំពីរ ដែលកាន់ពែងទាំងប្រាំពីរ
ពេញទៅដោយគ្រោះកាចទាំងប្រាំពីរ ចុងក្រោយ
បង្អស់បានចូលមកហើយពោលមកកាន់ខ្ញុំថា៖
«សូមអញ្ជើញមកខ្ញុំនឹងបង្ហាញឲ្យលោកឃើញ
កូនក្រមុំជាភរិយារបស់កូនចៀម»។

[១០]ទេវទូតនោះបានលើកវិញ្ញាណខ្ញុំឡើង
ទៅលើភ្នំមួយយ៉ាងធំខ្ពស់ រួចបង្ហាញឲ្យខ្ញុំឃើញ
ក្រុងដ៏វិសុទ្ធ ជាក្រុងយេរូសាឡឹមដែលចុះពី
ស្ថានបរមសុខ* គឺចុះមកពីព្រះជាម្ចាស់។
[១១] ក្រុងនេះប្រកបដោយសិរីរុងរឿងរបស់ព្រះជា
ម្ចាស់ ពន្លឺរស្មីរបស់ក្រុងប្រៀបបីដូចជាត្បូងដ៏
មានតម្លៃបំផុត គឺដូចត្បូងមណីជោតិរសដែលភ្លឺ
ថ្លាដូចកែវចរណៃ។ [១២]ក្រុងនេះមានកំពែងមួយ
យ៉ាងធំខ្ពស់ ព្រមទាំងមានខ្លោងទ្វារដប់ពីរនៅ
លើខ្លោងទ្វារមានទេវទូតដប់ពីររូប និងមាន
ចារឹកឈ្មោះកុលសម្ព័ន្ធទាំងដប់ពីររបស់ជនជាតិ
អ៊ីស្រាអែលដែរ។ [១៣]នៅទិសខាងកើតមាន
ខ្លោងទ្វារបី ទិសខាងជើងមានខ្លោងទ្វារបី ទិស
ខាងត្បូងមានខ្លោងទ្វារបី និងទិសខាងលិចមាន
ខ្លោងទ្វារបី។ [១៤]កំពែងរបស់ក្រុងមានគ្រឹះដប់ពីរ
ហើយនៅលើគ្រឹះទាំងនោះ មានចារឹកឈ្មោះ
គ្រីស្ដទូត*ទាំងដប់ពីររបស់កូនចៀម។

[១៥]ទេវទូតដែលនិយាយមកខ្ញុំនោះ កាន់
ត្រែងមាសមួយដើមធ្វើជារង្វាស់ សម្រាប់វាស់
ក្រុងខ្លោងទ្វារក្រុងនិងកំពែងក្រុង។ [១៦]ក្រុងនេះ
មានរាងបួនជ្រុងស្មើ គឺមានទទឹងនិងបណ្ដោយ
ស្មើគ្នា។ ទេវទូតបានយកដើមត្រែងនោះមក
វាស់ក្រុង ឃើញមានប្រវែងដប់ពីរពាន់ស្ដាដ[ល]។
បណ្ដោយទទឹងនិងកម្ពស់ មានប្រវែងស្មើៗគ្នា។
[១៧]ទេវទូតបានវាស់កំពែងដែរ ឃើញមានកម្ពស់
មួយរយសែសិបបួនហត្ថ[វ] តាមរង្វាស់មនុស្ស
លោក ដូចរង្វាស់ទេវទូតដែរ។ [១៨]កំពែងក្រុងធ្វើ
ពីត្បូងមណីជោតិរស ហើយទីក្រុងធ្វើពីមាស
សុទ្ធដែលភ្លឺថ្លាដូចកែវសុទ្ធ។ [១៩]គ្រឹះរបស់
កំពែងក្រុងមានតុបតែងទៅដោយត្បូងដ៏មាន
តម្លៃគ្រប់យ៉ាង គ្រឹះទីមួយធ្វើពីត្បូងមណីជោតិ
រស គ្រឹះទីពីរធ្វើពីត្បូងកណ្ដៀង គ្រឹះទីបីធ្វើពី
ត្បូងមោរ៉ាគ្រឹះទីបួនធ្វើពីកែវមរកត [២០]គ្រឹះទីប្រាំ
ធ្វើពីត្បូងដៃរគៀម គ្រឹះទីប្រាំមួយធ្វើពីត្បូងទទឹម
គ្រឹះទីប្រាំពីរធ្វើពីត្បូងប៊ុតលឿង គ្រឹះទីប្រាំបីធ្វើ
ពីត្បូងបេរីល គ្រឹះទីប្រាំបួនធ្វើពីត្បូងថៃលឿង
គ្រឹះទីដប់ធ្វើពីត្បូងកែវយក់ គ្រឹះទីដប់មួយធ្វើពី
ត្បូងនិលវ័ត្ត គ្រឹះទីដប់ពីរធ្វើពីត្បូងជម្ពូរត្ន។ [២១]

ទ្វារទាំងដប់ពីរធ្វើពីកែវមុក្តាដប់ពីរ គឺទ្វារនីមួយ
ៗធ្វើពីកែវមុក្តាតែមួយដុំ។ លានរបស់ក្រុងធ្វើពី
មាសសុទ្ធ ភ្លឺថ្លាដូចកែវ។

២២ខ្ញុំពុំឃើញមានព្រះវិហារ* នៅក្នុងទីក្រុង
ទេ ដ្បិតព្រះជាអម្ចាស់ដ៏មានព្រះចេស្ដាលើអ្វីៗ
ទាំងអស់ ព្រមទាំងកូនចៀមនេះហើយដែលជា
ព្រះវិហាររបស់ក្រុងនោះ។ ២៣ក្រុងនោះមិនត្រូវ
ការ ពន្លឺព្រះអាទិត្យឬព្រះច័ន្ទឡើយដ្បិតសិរី
រុងរឿងរបស់ព្រះជាម្ចាស់បំភ្លឺក្រុង ហើយកូន
ចៀមក៏ជាចង្កៀងរបស់ក្រុងដែរ។ ២៤ជាតិ
សាសន៍នានា នឹងដើរក្នុងពន្លឺរបស់ក្រុងនោះ
ហើយស្ដេចនានានឹងនាំរាជទ្រព្យ ចូលមកក្នុង
ក្រុងនោះដែរ[ស]។ ២៥ទ្វារក្រុងមិនដែលបិទនៅ
ពេលថ្ងៃឡើយ ហើយនៅទីនោះគ្មានយប់ទេ។
២៦គេនឹងនាំយកភោគទ្រព្យ និងអ្វីៗដ៏មានតម្លៃ
របស់ជាតិសាសន៍នានាមកដាក់ក្នុងក្រុងនោះ។
២៧គ្មានអ្វីមួយមិនបរិសុទ្ធ អាចចូលមកក្នុងក្រុង
នោះបានឡើយ ហើយអ្នកប្រព្រឹត្តអំពើគួរឲ្យ
ស្អប់ខ្ពើមឬអ្នកកុហកក៏ពុំអាចចូលបានដែរ គឺ
មានតែអ្នកដែលមានឈ្មោះកត់ទុក ក្នុងក្រាំងនៃ
បញ្ជីជីវិតរបស់កូនចៀមប៉ុណ្ណោះទើបអាចចូល
បាន។

១ទេវទូត*បង្ហាញ ឲ្យខ្ញុំឃើញទន្លេដែល
២២មានទឹក ផ្ដល់ជីវិតថ្លាដូចកែវចរណៃ ហូរ
ចេញមកពីបល្ល័ង្ករបស់ព្រះជាម្ចាស់ និងបល្ល័ង្ក
របស់កូនចៀម។ ២នៅចំកណ្ដាលលានក្រុងនិង
នៅមាត់ច្រាំងទាំងសងខាងរបស់ទន្លេនោះ មាន
ដើមឈើដែលផ្ដល់ជីវិតផ្លែដប់ពីរដងក្នុងមួយឆ្នាំ
គឺមានផ្លែរៀងរាល់ខែ។ រីឯស្លឹកឈើនោះជាថ្នាំ
សម្រាប់ព្យាបាលប្រជាជាតិនានាឲ្យបានជា[ហ]។
៣ក្នុងក្រុងនោះ អ្វីៗទាំងអស់នឹងលែងត្រូវ
បណ្ដាសាទៀតហើយ។ បល្ល័ង្ករបស់ព្រះជា
ម្ចាស់និងបល្ល័ង្ករបស់កូនចៀម ស្ថិតនៅក្នុងក្រុង
នោះ ហើយពួកអ្នកបម្រើរបស់ព្រះអង្គនាំគ្នា
គោរពថ្វាយបង្គំព្រះអង្គ[ឡ] ៤គេនឹងឃើញព្រះភ័
ក្ត្រព្រះអង្គ ហើយនៅលើថ្ងាសគេក៏មានដៅព្រះ
នាមព្រះអង្គដែរ។ ៥នៅក្រុងនោះគ្មានយប់
ទៀតទេ គេក៏លែងត្រូវការពន្លឺចង្កៀង ឬពន្លឺព្រះ
អាទិត្យទៀតដែរ ដ្បិតព្រះជាអម្ចាស់ទ្រង់ជាពន្លឺ
បំភ្លឺគេ ហើយគេនឹងគ្រងរាជ្យអស់កល្បជា
អង្វែងតរៀងទៅ។

## សេចក្ដីដាស់តឿនផ្សេងៗ

៦ទេវទូតពោលមកខ្ញុំថា៖ «ពាក្យទាំងនេះ
សុទ្ធតែជាពាក្យពិតគួរឲ្យជឿ។ ព្រះជាអម្ចាស់
ដែលប្រទានព្រះវិញ្ញាណដល់ពួកព្យាការី* ទ្រង់
បានចាត់ទេវទូតរបស់ព្រះអង្គ ឲ្យមកប្រាប់ពួក
អ្នកបម្រើព្រះអង្គដឹងអំពីហេតុការណ៍ ដែលត្រូវ
កើតមានក្នុងពេលឆាប់ៗខាងមុខ។

៧ព្រះយេស៊ូមានព្រះបន្ទូលថា៖"ចូរស្ដាប់
យើងនឹងមកដល់ក្នុងពេលឆាប់ៗ អ្នកណាប្រតិ
បត្តិតាមសេចក្ដី ដែលមានថ្លែងទុកក្នុងសៀវភៅ
នេះ អ្នកនោះមានសុភមង្គលហើយ!"»។

៨ខ្ញុំយ៉ូហាន ខ្ញុំបានឮនិងបានឃើញហេតុ
ការណ៍ទាំងនេះ។ ពេលខ្ញុំបានឮនិងបានឃើញ
ដូច្នេះហើយ ខ្ញុំក្រាបចុះនៅទៀបជើងទេវទូត
ដែលបានបង្ហាញឲ្យខ្ញុំឃើញនោះ បម្រុងនឹង
ថ្វាយបង្គំលោក ៩ក៏ប៉ុន្តែទេវទូតពោលមកខ្ញុំថា៖

«កុំថ្វាយបង្គំខ្ញុំអី! ខ្ញុំជាអ្នករួមការងារជាមួយ
លោកទេតើ ហើយខ្ញុំក៏រួមការងារជាមួយពួកព្យា
ការី ដែលជាបងប្អូនរបស់លោក និងជាមួយ
អស់អ្នកប្រតិបត្តិតាមសេចក្ដី ដែលមានចែងក្នុង
សៀវភៅនេះដែរ។ ត្រូវថ្វាយបង្គំព្រះជាម្ចាស់
វិញ!»។ ១០ទេវទូតពោលមកខ្ញុំទៀតថា៖«សូម
កុំលាក់[អ]សេចក្ដី ដែលមានថ្លែងទុកក្នុងសៀវភៅ
នេះឲ្យសោះ! ដ្បិតពេលកំណត់ជិតមកដល់ហើ
យ។ ១១អ្នកណាទុច្ចរិតឲ្យអ្នកនោះប្រព្រឹត្តអំពើ
ទុច្ចរិតតទៅមុខទៀតទៅ! អ្នកណាសៅហ្មង ឲ្យ
អ្នកនោះបន្តភាពសៅហ្មងតទៅមុខទៀតទៅ! រី
ឯអ្នកសុចរិតវិញត្រូវប្រព្រឹត្តអំពើសុចរិតថែម
ទៀតចុះ! រីឯអ្នកវិសុទ្ធហើយត្រូវរក្សាខ្លួនឲ្យ
កាន់តែវិសុទ្ធថែមទៀតចុះ!។ ១២ព្រះយេស៊ូមាន
ព្រះបន្ទូលថា៖ "ចូរស្ដាប់យើងនឹងមកដល់ក្នុង
ពេលឆាប់ៗ ទាំងយករង្វាន់មកចែកឲ្យម្នាក់ៗ
តាមអំពើដែលខ្លួនបានប្រព្រឹត្ត។ ១៣យើងជាអា
ល់ផានិងជាអូមេកា[ក] នៅមុនគេ និងនៅក្រោយ
គេបំផុតជាដើមដំបូង និងជាចុងបង្អស់។ ១៤អ្នក
ណាបោកអាវវែងរបស់ខ្លួនបានស្អាត អ្នកនោះ
មានសុភមង្គលហើយ គេនឹងមានសិទ្ធិបេះផ្លែពី
ដើមឈើដែលផ្ដល់ជីវិត ព្រមទាំងចូលទៅក្នុង
ក្រុងតាមទ្វារផង!។ ១៥រីឯពួកឆ្កែ ពួកគ្រូធ្មប់ ពួក
ប្រាសចាកសីលធម៌ ពួកសម្លាប់គេ ពួកថ្វាយ
បង្គំព្រះក្លែងក្លាយ និងអស់អ្នកដែលចូលចិត្ត
កុហក និងអនុវត្តតាមពាក្យកុហកនោះវិញ ត្រូវ
ចេញទៅក្រៅទៅ! ១៦យើងយេស៊ូយើងបាន
ចាត់ទេវទូត*របស់យើងឲ្យមកបញ្ជាក់សេចក្ដី
ទាំងនេះ ប្រាប់អ្នករាល់គ្នាអំពី[ខ]ព្រះសហគមន៍
នានា។ យើងជាពន្លកដែលដុះចេញពីពូជពង្ស
របស់ព្រះបាទដាវីឌ យើងជាផ្កាយព្រឹកដ៏ភ្លឺ
ចិញ្ចែង"»។

១៧ព្រះវិញ្ញាណនិងភរិយាថ្មោងថ្មី ពោល
ឡើងថា៖ «*សូមព្រះអង្គយាងមក!*»។

សូមឲ្យអស់អ្នកដែលបានឮពោលឡើងដែរ ថា៖ «*សូមព្រះអង្គយាងមក!*»។

អ្នកណាស្រេក សុំអញ្ជើញមក! អ្នកណាចង់បាន សុំអញ្ជើញមកទទួលទឹកដែលផ្ដល់ជីវិត ដោយមិនបាច់បង់ថ្លៃ!

១៨ខ្ញុំសូមបញ្ជាក់ប្រាប់អស់អ្នក ដែលបានឮ
ព្រះបន្ទូលថ្លែងទុកក្នុងសៀវភៅនេះថា បើ
នរណាម្នាក់បន្ថែមអ្វីមួយពីលើ ព្រះជាម្ចាស់នឹង
យកគ្រោះកាច ដែលមានរៀបរាប់ក្នុងសៀវភៅ
នេះមកដាក់លើអ្នកនោះថែមទៀតផង ១៩ហើយ
ប្រសិនបើ មាននរណាម្នាក់ដកហូតសេចក្ដីណា
មួយ ពីព្រះបន្ទូលដែលមានថ្លែងទុកក្នុងសៀវ
ភៅនេះ ព្រះជាម្ចាស់ក៏នឹងដកហូតចំណែកផ្លែ
របស់ដើមឈើ ដែលផ្ដល់ជីវិតពីអ្នកនោះដែរ
ហើយមិនឲ្យគេចូលទៅក្នុងក្រុង ដែលមានរៀប
រាប់ក្នុងសៀវភៅនេះឡើយ។

២០ព្រះអង្គដែលបានបញ្ជាក់សេចក្ដីទាំងនេះ
ទ្រង់មានព្រះបន្ទូលថា៖ «ពិតមែនហើយយើង
នឹងមកដល់ក្នុងពេលឆាប់ៗ!»។

អាម៉ែន! ព្រះអម្ចាស់យេស៊ូអើយ សូមយាងមក![គ]។

២១សូមព្រះអម្ចាស់យេស៊ូ ប្រណី
សន្ដោសដល់បងប្អូនទាំងអស់គ្នា!។៚

ក. សាការី១២.១០។•ខ. ក្នុងព្យញ្ជនៈក្រិកអក្សរ «អាល់ផា» នៅខាងដើមគេហើយ «អូមេកា» នៅចុងក្រោយគេដូចអក្សរ«ក» និងអក្សរ«អ» ក្នុងព្យញ្ជនៈខ្មែរដែរ។ ឃ្លានេះមានន័យថាព្រះអង្គជាដើមដំបូង និង ជាចុងបំផុត។

គ. គឺថ្ងៃអាទិត្យ។•ឃ. ពាក្យដើម: «ក្បាលនិងសក់» ។•ង. ឃ្លាដើម «ដូចរោមចៀមពណ៌សនិងដូចហិមៈ» ។ «ហិមៈ» គឺទឹកកកដែលមានពណ៌សធ្លាក់ចុះមកដូចព្រិលនៅស្រុកត្រជាក់ (ឧទាហរណ៍ហិមពាន្ត: កន្លែងដែលមានទឹកកក) ។•ច. ឃ្លាដើម«យើងកាន់កូនសោរបស់សេចក្តីស្លាប់និងស្ថានមច្ចុរាជ(ឬស្ថានមនុស្សស្លាប់)» ។

ឆ. ជាពួកគ្រីស្តបរិស័ទមួយក្រុមនៅសម័យនោះដែលវង្វេងចេញឆ្ងាយពីសេចក្តីពិត។•ជ. ចង់ប្រដូចទៅនឹងសួនអេដែន ដែលលោកអដាំនិងនាងអេវ៉ារស់នៅមុនពេលមនុស្សប្រព្រឹត្តអំពើបាប (កំណើតពិភពលោក/ លោកុប្បត្តិ២.៩) ។•ឈ. ឃ្លាដើម«អ្នកស្ថិតនៅជាប់នឹងឈ្មោះយើង» ។

ញ. ជំរឿនប្រជាជន(ជនគណនា) ៣១.១៦;២៥.១–២។

ដ. ពាក្យដើម«ឃ្វាល» ។•ឋ. «អ្វីៗ» ចង់សំដៅទៅលើគ្រីស្តបរិស័ទដែលនៅសល់ ឬជំនឿដែលសល់។•ឌ. អេសាយ ២២.២២។

ឍ. ពាក្យ«អាម៉ែន» មានន័យថារឹងប៉ឹងមាំទាំពិតប្រាកដពិតមែនហើយ» លោកយ៉ូហានប្រើពាក្យនេះទុកជាព្រះនាមមួយរបស់ព្រះយេស៊ូ។•ណ. ពាក្យនេះធ្វើឲ្យយើងគិតអំពីពិធីជប់លៀងព្រះអម្ចាស់(យ៉ូហាន១៣.២) ។

ត. អេសាយ៦.៣។

ថ. វិវរណៈប្រើពាក្យ«កូនចៀម» សំដៅទៅលើព្រះគ្រីស្តព្រោះព្រះអង្គបានសោយទិវង្គតនៅលើឈើឆ្កាងជាយញ្ញបូជារំដោះមនុស្សលោកឲ្យរួចពីបាប។ សូមអានយ៉ូហាន១.៣៦ដែរ។

ទ. ពាក្យដើម«ស្រូវសាលីមួយគីឡូថ្លៃមួយដួង* ស្រូវឱកបីគីឡូក៏ថ្លៃមួយដួងដែរ» ។ ឃ្លានេះមានន័យថានឹងកើតមានទុរ្ភិក្ស។•ធ. យើងអាចបកប្រែពាក្យនេះថា«ស្ថានមនុស្សស្លាប់» ក៏បាន។•ន. អេសេគីអែល១៤.២១។

ប. ហូសេ១០.៨(លូកា២៣.៣០) ។

ផ. មានន័យថាព្រះជាម្ចាស់គង់ជាមួយពួកគេជានិច្ចនិរន្តតទៅ។•ព. អេសាយ៤៩.១០។•ភ. អេសាយ២៥.៨។

ម. ពាក្យដើម«ទេវតានៃទីជម្រៅ» ។

យ. ដានីអែល១២.៧។

រ. ឃ្លាដើម«ក្រាំងនេះនឹងធ្វើឲ្យមានជាតិល្វីងក្នុងពោះអ្នក» ។•ល. អេសេគីអែល៣.៣។•វ. និមិត្តរូបនៃការកាន់ទុក្ខ។•ស. សាការី៤.២,៣,១១–១៤។•ហ. យើងអាចបកប្រែម៉្យាងទៀតថា: «ព្រះវិញ្ញាណដែលផ្តល់ជីវិត» ។

ឡ. ទំនុកតម្កើង២.៩។•អ. ឃ្លា«មួយវស្សាពីរវស្សា និងពាក់កណ្តាលវស្សា» នេះយើងអាចបកប្រែថា«បីឆ្នាំកន្លះ» ក៏បាន។ កន្លែងខ្លះមានប្រើពាក្យ«សែសិបពីរខែ» ឬ«មួយពាន់ពីររយហុកសិបថ្ងៃ»(វិវរណៈ១១.២,៣; ១២.៦) សំដៅទៅលើគ្រាលំបាកដែលព្រះសហគមន៍ត្រូវឆ្លងកាត់នៅផែនដីនេះ។

ក. ដានីអែល៧.២១។

ខ. «ស្ត្រីៗ» ចង់សំដៅទៅលើព្រះក្លែងក្លាយ។ ឃ្លានេះមានន័យថាមនុស្សទាំងមួយសែនបួនម៉ឺនបួនពាន់នាក់មិនបានក្បត់ព្រះជាម្ចាស់ ទៅគោរពថ្វាយបង្គំព្រះក្លែងក្លាយឡើយ។

គ. ឃ្លាដើម«ឲ្យជាតិសាសន៍ទាំងអស់ផឹកស្រានៃសេចក្តីកំហឹងនៃកាមគុណថោកទាបរបស់វា» ។ យើងអាចបកប្រែឃ្លានេះតាមរបៀបមួយទៀតថា៖«ដែលបាននាំមនុស្សគ្រប់ជាតិសាសន៍ឲ្យក្បត់ព្រះជាម្ចាស់និងទទួលទោសពីព្រះអង្គ» ។•ឃ. ឃ្លាដើម: «អ្នកនោះនឹងផឹកស្រានៃសេចក្តីកំរោលរបស់ព្រះជាម្ចាស់គឺជាស្រាឥតលាយនៅក្នុងពែងនៃព្រះពិរោធរបស់ព្រះអង្គ» ។•ង. ការច្រូត និង ការបេះផ្លែទំពាំងបាយជូរជានិមិត្តរូបនៃការវិនិច្ឆ័យទោសនៅគ្រាចុងក្រោយ។•ច. ពាក្យដើម: «កណ្តៀវ» ។

ឆ. ប្រមាណ៣០០គ.ម.។ ស្តាដ(សតាដេ)ជារង្វាស់នៅសម័យដើមមួយស្តាដ=១៨៥ម៉ែត្រ។•ជ. ព្រះពន្លានៃសក្ខីភាពនេះបញ្ជាក់អំពីវត្តមានរបស់ព្រះជាម្ចាស់ជាមួយជនជាតិអ៊ីស្រាអែ

ល។

ឈ.«ផឹកស្រាពីពែងនៃព្រះពិរោធ» សំដៅទៅលើទារុណកម្មដ៏ធ្ងន់ដែលក្រុងរ៉ូមត្រូវទទួល។•ញ.ពាក្យដើម«តាឡឺនតុន»(១តាឡឺនតុន=៣៤,២៧២គ.ក្រ.)។ ទម្ងន់ខ្មែរមួយចុងមានទម្ងន់ជាង៣០គ.ក្រ.(យើងអាចប្រែថាកន្លះហាបក៏បាន)។

ដ. អេសាយ២១.៩។•ឋ.ឃ្លាដើម«សាសន៍ទាំងប៉ុន្មានបាននាំគ្នាផឹកស្រានៃសេចក្តីកំហឹងរបស់អំពើថោកទាបរបស់ក្រុងនេះ»។•ឌ. យេរេមី៥១.៤៥។

ឍ.អេសាយ៤៧.៨។•ណ. សម្បុរល្វែងជាឈ្មោះឈើមួយប្រភេទដែលសំបកវាមានក្លិនក្រអូបប្រហើរ។•ត.«អ្នកងារនិងអ្នកជាប់ឈ្លើយ»: ពាក្យដើម«រូបកាយនិងព្រលឹងរបស់មនុស្ស» សំដៅទៅលើអ្នកងារដែលនៅជំនាន់នោះត្រូវគេយកទៅលក់ដូរដូចសត្វឬដូចទំនិញឯទៀតៗដែរ។•ថ. អេសេគីអែល២៧.២៩។

ទ. យេរេមី៥១.៦៤។•ធ.ជាពាក្យហេប្រឺដែលមានន័យថា«សរសើរតម្កើងព្រះជាម្ចាស់!»។

ន.ភរិយាថ្មោងថ្មីរបស់កូនចៀម(ព្រះគ្រីស្ត) គឺសំដៅទៅព្រះសហគមន៍របស់ព្រះអង្គ។•ប.ឬវិញ្ញាណដែលស្ថិតនៅក្នុងព្យាការី។•ផ. ទំនុកតម្កើង២.៩។

ព. សូមអានកំណើតពិភពលោក៣.១។•ភ.សូមអានវិវរណៈ១៣.១៥-១៦។•ម.ក្នុងគម្ពីរសម្ពន្ធមេត្រីចាស់មានម្នាក់ក្នុងកុលសម្ព័ន្ធរូបេនឈ្មោះកុក(១របាក្សត្រ៥.៤)និងមានម្នាក់ទៀតឈ្មោះម៉ាកុកជាកូនចៅរបស់លោកយ៉ាផេត(កណ. ១០.២)។ ក្នុងគម្ពីរអេសេគីអែល៣៨-៣៩ មានថ្លែងអំពីកុកដែលត្រូវជាស្ដេចរបស់ម៉ាកុកវាយលុកប្រទេសអ៊ីស្រាអែលដែលទើបនឹងបានកកើតឡើងវិញ។ ក្នុងអត្ថបទនេះ កុក និង ម៉ាកុកសំដៅទៅលើប្រជាជាតិផ្សេងៗ ដែលប្រឆាំងនឹងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ តែប្រជាជាតិទាំងនោះនឹងត្រូវបរាជ័យនៅគ្រាអវសានកាលនៃពិភពលោក។•យ. មានន័យថា«ព្រះជាម្ចាស់គង់នៅកណ្ដាលចំណោមប្រជារាស្ត្ររបស់ព្រះអង្គដើម្បីការពារនិងដឹកនាំគេ»។ យើងអាចយល់ឃ្លានេះថា«អេម៉ានូអែល» ឬថា«ព្រះអម្ចាស់យាងមកគង់ជាមួយយើង» ក៏បាន(សូមអានម៉ាថាយ១.២៣ ; យ៉ូហាន១.១៤)។

រ. សូមអានសេចក្តីពន្យល់«ខ»នៅ១.៨។•ល. សូមអានសេចក្តីពន្យល់នៅវិវរណៈ១៤.២០។•វ. ឬ៧២ម៉ែត្រ។

ស. អេសាយ៦០.៣-៥។•ហ.អេសេគីអែល៤៧.១២។•ឡ. យើងអាចបកប្រែថា«គោរពបម្រើព្រះអង្គ» ក៏បាន។

អ.ពាក្យដើម«កុំបិទត្រាលើ»។•ក.សូមអានសេចក្តីពន្យល់នៅវិវរណៈ១. ៨។•ខ. យើងអាចបកប្រែថា៖«នៅក្នុងព្រះសហគមន៍នានា»ក៏បាន។•គ ក្នុងឯកសារដើមជាភាសាក្រិកឃ្លានេះមានសរសេរជាភាសាអារ៉ាមថា«ម៉ារ៉ាណាថា!»។